សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

CAMBODIAN WATER SUPPLY ASSOCIATION

# របាយការណ៍ប្រចាំឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥

# ANNUAL REPORT 2024 AND PLANNING 2025



# មាតិកា


១. អំពីសមាគម ....................................................................................................1

១.១ សេចក្តីផ្តើម....................................................................................................1

១.២ ទស្សនវិស័យ និងបេសកកម្ម ..............................................................................2

១.៣ ផែនការយុទ្ធសាស្ត្រ .........................................................................................2

២. អភិបាលកិច្ច ....................................................................................................2

២.១ សន្និបាតប្រចាំឆ្នាំ២០២៣...................................................................................2

២.២ សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥ .....................................................4

២.៣ សិក្ខាសាលាពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា.......................6

២.៤ លទ្ធផលការងារក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ .....................................7

២.៤.១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស...........................................................7

២.៤.២ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល ..........................................................8

២.៤.៣ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៣.....................................................................9

២.៤.៤ ការចូលជួបសម្តែងការគួរសម...........................................................................10

៣. ការងារជាមួយសមាជិក ....................................................................................11

៣.១ អំពីសមាជិកភាព .............................................................................................11

៣.១.១ ការចូលជាសមាជិកថ្មីរបស់សមាគម ....................................................................11

៣.១.២ ការបាត់បង់សមាជិកភាព.................................................................................12

៣.២ កិច្ចប្រជុំថ្នាក់តំបន់............................................................................................13

៣.៣ កិច្ចគាំពារសមាជិក............................................................................................17

៣.៣.១ បញ្ហាខូចខាតបណ្តាញបំពង់ទឹកស្អាត .................................................................17

៣.៣.២ ការសម្របសម្រួល និងដោះស្រាយបញ្ហាប្រកពទឹក..................................................19

៣.៤ កិច្ចគាំទ្រជំនួយផ្នែកបច្ចេកទេស .............................................................................20

៣.៤.១ ការធ្វើផ្សារតេស្ត និងវិភាគគុណភាពទឹក..............................................................20

៣.៤.២ កម្មវិធីកសាងសមត្ថភាព .................................................................................21

៣.៥ ការចុះសួរសុខទុក្ខសមាជិក...................................................................................24

៣.៦ កម្មវិធីផ្សព្វផ្សាយអំពីសេវាកម្មទឹកស្អាតរបស់សមាជិក ..............................................26

៣.៧ ដំណើរកម្សាន្ត និងទស្សនសិក្សារបស់សមាជិក ....... 26

៣.៧.១ ដំណើរកម្សាន្ត និងទស្សនកិច្ចសិក្សាក្នុងប្រទេស ....... 26

៣.៧.២ ដំណើរកម្សាន្តក្រៅប្រទេស ....... 30

៤. ភាពជាតំណាងឱ្យសមាជិក ....... 31

៤.១ កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ....... 31

៤.១.១ កិច្ចសហប្រតិបត្តិការជាមួយក្រសួង/មន្ទីរ ឧ.វ.ប.ន ....... 31

៤.១.២ កិច្ចសហប្រតិបត្តិការជាមួយក្រសួង និងដៃគូអភិវឌ្ឍន៍នានា ....... 34

៤.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ ....... 35

៤.២.១ សិក្ខាសាលាស្តីពី«ប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត» ....... 35

៤.២.២ សិក្ខាសាលាទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន ....... 36

៤.២.៣ កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនអន្តរជាតិ ....... 38

៤.២.៤ សិក្ខាសាលាស្តីពី បច្ចេកទេសប្រព័ន្ធចម្រោះទឹក ....... 39

៤.២.៥ ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ....... 39

៤.២.៦ សន្និសីទ និងពិព័រណ៍ទឹកអន្តរជាតិ ....... 42

៤.២.៧ ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ....... 47

៥. ការងារសហការជាមួយដៃគូអភិវឌ្ឍន៍ ....... 48

៥.១ គម្រោង«ពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត» គាំទ្រដោយអង្គការ Water.org ....... 48

៥.១.១ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ ....... 48

៥.១.២ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស ....... 49

៥.១.៣ ការចូលរួមវេទិកាអន្តរជាតិ ....... 52

៥.១.៤ ការសម្របសម្រួលកម្ចី ....... 53

៥.១.៥ ការសិក្សាផែនការមេ និងផែនការអាជីវកម្ម ....... 55

៥.១.៦ កិច្ចសម្ភាសជាមួយប្រតិបត្តិករ និងគ្រួសារដែលបានប្រើប្រាស់ទឹកស្អាត ....... 55

៥.១.៧ កិច្ចសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត ....... 56

៥.១.៨ កិច្ចប្រជុំក្នុងគម្រោង ....... 57

៥.១.៩ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង ....... 58

៥.២ គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន» គាំទ្រដោយអង្គការ EMW ....................59
៥.៣ គម្រោង«ការពង្រឹងសមត្ថិភាពប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងការកសាងសមត្ថភាពអាជ្ញាធរពីការប្រែប្រួលអាកាសធាតុ សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត»គាំទ្រដោយ UTS ....................61
៥.៣.១ ការចុះបង្ហឹកដល់ស្ថានីយ ....................61
៥.៣.២ ការត្រួតពិនិត្យ និងតាមដាន ....................62
៥.៣.៣ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង ....................62
៥.៤. គម្រោង«ជ្រើសរើសប្រតិបត្តិករឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត» គាំទ្រដោយអង្គការ JICA ....................63
៦. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ....................67
៧. បញ្ហាប្រឈម ....................67
៧.១ បញ្ហាប្រឈមរបស់វិស័យទឹកស្អាត ....................67
៧.២ បញ្ហាប្រឈមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ....................68
៧.៣ បញ្ហាប្រឈមរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ....................68
៨. ទិសដៅការងារអនុវត្តឆ្នាំ២០២៥ ....................68
៨.១ អភិបាលកិច្ច ....................68
៨.២ ការងារជាមួយសមាជិក ....................69
៨.៣ កិច្ចសហការជាតិ និងអន្តរជាតិ ....................69
៨.៤ ការងារសហការជាមួយដៃគូអភិវឌ្ឍន៍ ....................69
៨.៥ រដ្ឋបាល និងហិរញ្ញវត្ថុ ....................69

# របាយការណ៍បូកសរុបលទ្ធផលការងារសមាគមប្រចាំឆ្នាំ២០២៤ និងទិសដៅការងារសម្រាប់ឆ្នាំ២០២៥

ក្នុងឆ្នាំ២០២៤ សមាគមបានបន្តអនុវត្តតាមផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ ២០២០-២០២៤ ដោយបានសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) ពិសេសអគ្គនាយកដ្ឋានទឹកស្អាត ក៏ដូចជាដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រដល់ការងាររបស់សមាគម។ សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៤ រួមមាន៖

១). រៀបចំសន្និបាតប្រចាំឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុប សរុបចំនួន ៤១៥នាក់ (ស្រី ១១៥នាក់)។ ក្នុងនោះសន្និបាតលើកទី១២ បានជ្រើសរើស ក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី២ សម្រាប់សមាគមនិតីបុគ្គល (ឆ្នាំ២០២៤-២០២៧) មានចំនួន ៩រូប (ស្រី ២រូប)។

២). សហការជាមួយក្រសួង ឧ.វ.ប.ន. និង Informa Market ក្នុងការរៀបចំសិក្ខាសាលា និងពិព័រណ៍ឧស្សាហកម្មវិស័យសំណង់ អគារ វិស្វកម្ម និងឧស្សាហកម្មវិស័យទឹកខ្នាតអន្តរជាតិធំជាងគេនៅកម្ពុជា ២០២៤។

៣). រៀបចំសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥ ដែលមានអ្នកចូលរួមសរុប ៦៦៨នាក់ (ស្រី ២០៥នាក់)។

៤). រៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ៥លើក នៅទីតាំងដូចជា៖ ខេត្តសៀមរាប កំពង់ចាម កំពង់ស្ពឺ បាត់ដំបង និងរាជធានីភ្នំពេញ។ អ្នកចូលរួមសរុបទាំង៥ កិច្ចប្រជុំមានចំនួន ៤៤០នាក់(ស្រី ៨៧នាក់)។

៥). រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលចំនួន ៩លើក ដើម្បីពិនិត្យមើលការងារប្រតិបត្តិរបស់សមាគម និងផែនការបន្ទាប់ ព្រមទាំងពិភាក្សាស្វែងយល់អំពីបញ្ហាប្រឈម និងដំណោះស្រាយសមាជិកដែលបាននឹងកំពុងជួបប្រទះ។

៦). រៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ឆ្នាំ២០២៥ - ២០៣០ ដែលទទួលបានការគាំទ្រពីកម្មវិធី CAPRED និងសមាគមទឹកអូស្ត្រាលី AWA។

៧). កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ៖ សមាគមបានចូលរួមសន្និបាតប្រចាំឆ្នាំ២០២៣ របស់ក្រសួងឧ.វ.ប.ន. និងចូលរួមកិច្ចពិភាក្សាតុមូលស្តីពី«ការលើកកម្ពស់វិស័យសម្រាប់លទ្ធភាពទទួលបានទឹកស្អាតដោយសមធម៌នៅកម្ពុជា»។ ជាងនេះទៅទៀត សមាគមបានដឹកនាំសមាជិកចូលរួមសិក្ខាសាលាស្តីពី«ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន» ឆ្នាំ២០២៤ និងបានរៀបចំទស្សនកិច្ចសិក្សាជូនគណៈប្រតិភូសាធារណរដ្ឋឥណ្ឌាដើម្បីស្វែងយល់ពីប្រព័ន្ធទឹកស្អាត និងទឹកកខ្វក់នៅកម្ពុជា។ បន្ថែមពីនេះ សមាគមបានដឹកនាំសមាជិកចូលរួមកម្មវិធីនៅក្រៅប្រទេសដូចជា៖ ក).វេទិកាទឹកពិភពលើកទី១០ នៅប្រទេសឥណ្ឌូនេស៊ី ខ).សន្និសីទ និងពិព័រណ៍ទឹក នៅប្រទេម៉ាឡេស៊ី ថៃ ឥណ្ឌូនេស៊ី និងវៀតណាម គ).វេទិកាទឹក (Water Week) នៅប្រទេសវៀតណាម ឃ).ទស្សនកិច្ចសិក្សារោងចក្រផលិតសម្ភារៈទឹកស្អាតវៃឆ្លាត WPG (Shanghai) Smart Water Public Co., Ltd នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ង).វេទិកាហិរញ្ញប្បទានសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម នៅប្រទេសហ្វីលីពីន និង ច).ដំណើរកម្សាន្តជូនសមាជិកទៅទស្សនា កោះត្រល់ ប្រទេសវៀតណាម។

៨). សមាគមបានដឹកនាំសមាជិកទៅទស្សនកិច្ចសិក្សានៅក្នុងប្រទេសបានចំនួន ៥លើក រួមមាន៖ ក).ក្រុមហ៊ុនខោលបុល ទឹកស្អាត ឯ.ក និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ-រោងចក្រផលិតទឹកស្អាតម្លេច ខ).ស្ថានីយផ្គត់ផ្គង់

ទឹកស្អាត ពកត្របែក និងរដ្ឋាករទឹកកំពត គ).ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបហ៊ុយ ឃ).រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ-រោងចក្រផលិតទឹកស្អាត បាក់ខែង និង ង).ស្ថានីយផលិតទឹកស្អាតស្វាយរមៀត។

៩). ផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេទេសចំនួន ៤វគ្គ លើប្រធានបទ ក).ការគ្រប់គ្រងទឹកបាត់បង់ និងបច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ខ).វិធីសាស្ត្រធ្វើជួរតេស្ត និងការវិភាគគុណភាពទឹកស្អាត និង គ).ការសន្សំសំចៃថាមពលសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជន។

១០). សមាគមបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ សមាគមទឹកអូស្ត្រាលី (AWA) លើកិច្ចសហប្រតិបត្តិការសម្រាប់រយៈពេល ៣ឆ្នាំ និងជាមួយ សមាគមអាជីវកម្មទឹកក្រៅប្រទេសក្រុងគីតាយ្យូស៊ុ (KOWBA) សម្រាប់រយៈពេល ៥ឆ្នាំ។

១១). សមាគមបានចូលរួមសម្របសម្រួលដោះស្រាយបញ្ហាខូចខាតបំពង់ទឹកស្អាតចំនួន ៣ស្ថានីយ និងបញ្ហាប្រភពទឹក ១ស្ថានីយ។ ជាងនេះទៅទៀតសមាគមបានចុះសួរសុខទុក្ខសមាជិកបាន ៤៨ស្ថានីយ ក្នុងនោះគាំទ្រដោយអង្គការ Water.org ចំនួន ៣១ស្ថានីយ។

១២). សមាគមបានអនុវត្តគម្រោងជាមួយអង្គការដៃគូរួមមាន៖ អង្គការ Water.org អង្គការ East Meets West (EMW) និង University of Technology Sydney (UTS) ដើម្បីជួយគាំទ្រទៅដល់សមាជិក។

១៣). សមាគមទទួលបានលិខិតអនុញ្ញាតលើកលែងពន្ធលើប្រាក់ចំណូលពី **អគ្គនាយកដ្ឋានពន្ធដារ** និងបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤។

សម្រាប់ឆ្នាំ២០២៥ សមាគមនឹងទទួលបានផែនការយុទ្ធសាស្ត្រថ្មីសម្រាប់ឆ្នាំ២០២៥-២០៣០ ដោយផ្តោតទៅលើ៖ ១).ការពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងនិរន្តរភាពរបស់សមាជិក ២).បង្កើនគុណភាពនៃការចូលរួមរបស់សមាជិក និងសេវាកម្មផ្តោតលើគុណតម្លៃរបស់សមាជិក ៣).លើកកម្ពស់ភាពជាតំណាងសមាជិកប្រកបដោយប្រសិទ្ធភាព និងស្វែងរកការគាំទ្រមតិ និង ៤).ពង្រឹងសមត្ថភាពស្ថាប័ន និងនិរន្តរភាពហិរញ្ញវត្ថុរបស់សមាគម ដើម្បីផ្តល់សេវាកម្មតាមប្រកបដោយប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរបស់សមាជិក និងជាតំណាងសមាជិកដោយប្រសិទ្ធភាព។

# ១. អំពីសមាគម

## ១.១ សេចក្តីផ្តើម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក) ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណ ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី (MSME) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃតាមសេចក្តីជូនដំណឹងលេខ៖ ១០៧៧ សជណ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ៖ ២៩០១ ប្រក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល មានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

ក្នុងឆ្នាំ២០២៤ សមាគមមានសមាសភាពក្រុមប្រឹក្សាភិបាលចំនួន ៩រូប (ស្រី ១រូប) ដែលមានរចនាសម្ព័ន្ធ៖ ប្រធាន ១រូប អនុប្រធាន ១រូប ហេរញ្ញិក ១រូប និងសមាជិកចំនួន ៦រូប។ សមាគមមានបុគ្គលិកសរុបចំនួន ៩រូប (ស្រី ៤រូប) និងមានសមាជិកសរុបចំនួន ៣២២ស្ថានីយ/ក្រុមហ៊ុន ដែលក្នុងនោះមាន ២៧៦ស្ថានីយ បាននឹងកំពុងប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

**ទស្សនៈវិស័យ**




ចង់ឃើញប្រជាពលរដ្ឋកម្ពុជា នៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជា ទទួលបានសេវាទឹកស្អាត និងអនាម័យ ដែលមានគុណភាពស្របតាមស្តង់ដាថ្នាក់ជាតិ។



## ១.២ ទស្សនវិស័យ និងបេសកកម្ម

| បេសកកម្ម | |
|---|---|
| ១ | គាំទ្រ និងលើកកម្ពស់ការជួយគ្នាទៅវិញទៅមករវាងអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា |
| ២ | បង្កើនចំណេះដឹង បច្ចេកទេសស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ និង |
| ៣ | ជំរុញឱ្យមាននិរន្តភាព និងការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។ |

## ១.៣ ផែនការយុទ្ធសាស្ត្រ

ក្នុងឆ្នាំ២០២៤ សមាគមបានបន្តអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២០ -២០២៤ ដូចខាងក្រោម៖

១
- ការពារ និងពង្រឹងសមត្ថភាពសមាជិករបស់ខ្លួន

២
- ធ្វើឱ្យមាននិរន្តរភាពហិរញ្ញវត្ថុរបស់សមាគម

៣
- ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត។

# ២. អភិបាលកិច្ច

## ២.១ សន្និបាតប្រចាំឆ្នាំ២០២៣

សន្និបាតសមាគមលើកទី១២ ប្រចាំឆ្នាំ២០២៣ បានប្រារព្ធឡើងនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤ នៅភោជនីយដ្ឋានទន្លេបាសាក់២ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) និង **ឯកឧត្តម ចាស់ស្ទីន វ៉ាយអេដ** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។




*រូបភាពទី១- កម្មវិធីបើកសន្និបាតលើកទី១២*

សន្និបាតលើកទី១២ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន. ក្រសួងអភិវឌ្ឍន៍ជនបទ ស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ស្ថានទូតចក្រភពអង់គ្លេស អង្គការ Water.org កម្មវិធី CAPRED ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល និងសេវាកម្ម និងសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សរុបចំនួន ៤១៥នាក់ (ស្រី ១១៥នាក់)។ សន្និបាតនេះក៏មានការតាំងបង្ហាញផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងវិស័យទឹកស្អាតផងដែរ។

សន្និបាតលើកទី១២ នេះបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលសមាគមសម្រាប់អាណត្តិទី២ (២០២៤-២០២៧)។ បេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាភិបាលមានចំនួន ១៣រូប (ស្រី ៣រូប)។ លទ្ធផលនៃការបោះឆ្នោតបានបង្ហាញក្នុងតារាងខាងក្រោម៖

*តារាងទី១ - បេក្ខជនឈរឈ្មោះជាក្រុមប្រឹក្សាភិបាល និងលទ្ធផលបោះឆ្នោត*

| លេខរៀងបេក្ខជន | ឈ្មោះបេក្ខជន | ចំនួនសន្លឹកឆ្នោត | លេខលំដាប់ | លទ្ធផល |
|---|---|---|---|---|
| ១ | លោក ជា សំបូរ | ៩៥ | ៨ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |
| ២ | លោក ចាន់ ថានី | ៩៥ | ៨ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |
| ៣ | លោក មួង ដារ៉ាវី | ៧២ | ១១ | |
| ៤ | អ្នកស្រី ហាក់ សេងថា | ៥៦ | ១២ | |
| ៥ | លោក ហម ងួន | ១០៨ | ៤ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |
| ៦ | អ្នកស្រី យ៉ាន ធីតា | ១០៣ | ៥ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |
| ៧ | លោក រី ខេមឬទ្ធិ | ៦៨ | | |
| **៨** | **អ្នកស្រី ស៊ីម សៀមនី** | **១១៩** | **២** | ជាប់ជាអនុប្រធានក្រុមប្រឹក្សាភិបាល |
| ៩ | លោក ហៀក អេងឡាយ | ៨០ | ១០ | ជាប់ជាសមាជិកបំរុង |
| ១០ | លោក សៀវ ហួត | ១០០ | ៦ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |
| **១១** | **លោក ឡេង ឌៀវ** | **១៤៣** | **១** | ជាប់ជាប្រធានក្រុមប្រឹក្សាភិបាល |
| ១២ | លោក លាង បញ្ញា | ៩៨ | ៧ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |
| ១៣ | លោក សៀ សេងហ៊ាប | ១១០ | ៣ | ជាប់ជាសមាជិកក្រុមប្រឹក្សាភិបាល |

យោងតាមលទ្ធផលនេះ **លោក ឡេង ខៀវ** ទទួលបានលេខរៀងទី១ មានសំឡេងឆ្នោតគាំទ្រ ១៤៣សំឡេង ជាប់ជាប្រធានក្រុមប្រឹក្សាភិបាល និង **លោកស្រី ស៊ឹម សៀមនី** ទទួលបានលេខរៀងទី២ មានសំឡេងឆ្នោតគាំទ្រ ១១៩ សំឡេង ជាប់ជាអនុប្រធានក្រុមប្រឹក្សាភិបាល។

សន្និបាតទទួលបានការសហការឧបត្ថម្ភពី អង្គការ Water.org កម្មវិធី CAPRED និងក្រុមហ៊ុន ១៨ ផ្សេងទៀត រួមមាន៖ ១).ក្រុមហ៊ុន ធី អ៊ី អឹម ខូអិលធីឌី (TEM) ២).ក្រុមហ៊ុន វ៉តធើម៉ិច ថេកណូឡជី (Watermech) ៣).ក្រុមហ៊ុន Representative Office of Fuji Electric Co., Ltd ៤).សហគ្រាសអ៊ី-ផៅវ័រ ស៊ីស៊ីអិល (E-Power) ៥).ក្រុមហ៊ុន អិកវ៉ធើរថេកណូឡជី (X-Water) ៦).ក្រុមហ៊ុន ធីស៊ីយូប៉ូលីអេធើប្រាយ (TCU) ៧).ក្រុមហ៊ុនភ្នំពេញប្លាស្ទិចប្រូដាក់ (Phnom Penh Plastic) ៨).ក្រុមហ៊ុនឌីនីម៉ិច (Dhinimex) ៩).ក្រុមហ៊ុនវ៉ធើរ ផាតនើរ (ខេមបូឌា) ឯ.ក ១០).ក្រុមហ៊ុន ខេស៊ីអេរអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក (KCRI) ១១).ក្រុមហ៊ុន លេសសូ (ខេមបូឌា) ត្រេឌីង ឯ.ក (LESSO) ១២).ក្រុមហ៊ុន Petram Design International ១៣).ក្រុមហ៊ុន ឥន្ទនូ ខេមបូឌាត្រេឌីង ១៤).ក្រុមហ៊ុន GEOCRAFT Co.,Ltd ១៥).ធនាគារ Foreign Trade Bank of Cambodia (FTB) ១៦).ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME) ១៧).Stone Family Foundation និង ១៨).មីក្រូហិរញ្ញវត្ថុ LOLC។




*រូបភាពទី២- សមាជិក សមាជិកាក្នុងសន្និបាតលើកទី១២*

## ២.២ សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជាលើកទី៥

ថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានសហការជាមួយ ក្រសួង ឧ.វ.ប.ន. រៀបចំសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥ ឆ្នាំ២០២៤ ក្រោមប្រធានបទ«**ទឹកដើម្បីនិរន្តរភាពអនាគត**»។ សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥ ក្រោមកិច្ចគាំទ្រពីកម្មវិធី CAPRED និងសមាគមទឹកអូស្ត្រាលី (AWA) យើងបានរៀបចំប្រធានបទសំខាន់ៗ ដែលទាក់ទងទៅនឹងតម្រូវការបច្ចុប្បន្នសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងបានអញ្ជើញវាគ្មិន នៅក្នុងស្រុក និងក្រៅស្រុក ដែលមានចំណេះដឹង បំណិន និងបទពិសោធន៍ការងារលើវិស័យទឹក ពិសេសការផ្គត់ផ្គង់ទឹកស្អាត មកពិភាក្សា និងធ្វើបទបង្ហាញ ដើម្បីចែករំលែកបទពិសោធន៍ ចំណេះដឹង បំណិន និងបច្ចេកវិទ្យាថ្មីៗជូនដល់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីអ្នកនាងកញ្ញា ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ ប្រតិបត្តិករ និងប្អូនៗនិស្សិត ទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនេះ។ ជាងនេះទៅទៀត សមាគមក៏បានរៀបចំឱ្យមានការដាក់តាំងពិព័រណ៍ផលិតផល និងសេវាកម្មបច្ចេកវិទ្យាថ្មីៗសម្រាប់វិស័យទឹកស្អាតផងដែរ។

សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥នេះ ទទួលបានកិត្តិយសអញ្ជើញចូលរួមជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហេម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួង ឧ.វ.ប.ន. **ឯកឧត្តម ដេរិក យីប** ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅកម្ពុជា **លោកស្រី ខូរីន ឆេសមែន** នាយិកាសមាគមទឹកអូស្ត្រាលី **លោក ឡេង ខៀវ** ប្រធានសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និងមានអ្នកចូលរួមសរុបចំនួន ៦៦៨នាក់ (ស្រី ២០៥នាក់) ថ្ងៃទី១៖ សរុប ៣៨៩នាក់ ស្រី ១២៣នាក់ និងថ្ងៃទី២៖ សរុប ២៧៩នាក់ ស្រី ៨២នាក់។




*រូបភាពទី៣- ការផ្តល់កិត្តិយសកាត់ខ្សែបូដោយ **ឯកឧត្តម ហេម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួង ឧ.វ.ប.ន.*

សន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥ ទទួលបានការចូលរួមគាំទ្រពីដៃគូសហការចំនួន ៧ស្ថាប័ន រួមមាន៖ ១).កម្មវិធី CAPRED ២).ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុន (JICA) ៣).អង្គការ Water.org ៤).សកលវិទ្យាល័យបច្ចេកទេសស៊ីដនី (UTS) ៥).ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME BANK) ៦).ក្រុមហ៊ុន iSEA ៧).អង្គការ WaterAid ព្រមទាំងដៃគូសហការឧបត្ថម្ភចំនួន ១៣ រួមមាន៖ ១).សមាគមទឹកអូស្ត្រាលី (AWA) ២).សមាគមអាជីវកម្មទឹកក្រៅប្រទេសក្រុងគីតាយូស៊ូ (KOWBA) ៣).ក្រុមហ៊ុន លេសសូ(ខេមបូឌា) ត្រេឌីង ឯ.ក ៤).ក្រុមហ៊ុន Molecor Southeast Asia ៥).ក្រុមហ៊ុនវ៉ាធើម៉ិច ថេកណូឡូជី ៦).សហគ្រាស អ៊ី-ផៅវ័រ ស៊ីស៊ីអិល ៧).ក្រុមហ៊ុន ខេស៊ីអអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក ៨).ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA) ៩).ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ១០).ធនាគារកាណាឌីយ៉ា (CANADIA) ១១).គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេអឹមខេ ភីអ៊ិលស៊ី (AMK) ១២).ក្រុមហ៊ុន KRL Industries និង ១៣).ក្រុមហ៊ុន អិកវ៉ាធើរ ថេកណូឡូជី (X-Water)។



*រូបភាពទី៤- រូបភាពអនុស្សាវរីយ៍ក្នុងសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥*

## ២.៣ សិក្ខាសាលាពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ តាមរយៈការគាំទ្ររបស់កម្មវិធី CAPRED សមាគមបានរៀបចំសិក្ខាសាលា **«ពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា»** នៅសណ្ឋាគារ Cambodiana រាជធានីភ្នំពេញ សម្របសម្រួលដោយ **លោក ផល វ៉ាន់ឌី** ទីប្រឹក្សាផ្នែកការអភិវឌ្ឍស្ថាប័ននៃកម្មវិធី CAPRED។ សិក្ខាសាលានេះមានការចូលរួមពីក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម សមាជិកអាជីព និងសមាជិកគាំទ្រ បុគ្គលិកកម្មវិធី CAPRED សរុបចំនួន ៣១នាក់ (ស្រី ១១នាក់)។ គោលបំណងនៃសិក្ខាសាលារួមមាន៖

១. ធ្វើបទបង្ហាញ និងពិភាក្សាអំពីចក្ខុវិស័យ បេសកកម្ម ការកំណត់អាទិភាពនៃតួនាទី និងការទទួលខុសត្រូវរបស់សមាគម
២. ឆ្លុះបញ្ចាំងពីការរកឃើញ នៃការធ្វើបច្ចុប្បន្នភាពស្ថានភាពពាក់ព័ន្ធ និងនិន្នាសំខាន់ៗទាក់ទងនឹង សមាគម និងប្រតិបត្តិករ
៣. ឆ្លុះបញ្ចាំងពីសមាគមលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង (ការវិភាគ SWOT) ដើម្បីបញ្ជាក់ពីការធ្វើរោគវិនិច្ឆ័យរបស់សមាគម
៤. កំណត់សកម្មភាពកែលម្អសំខាន់ៗតាមរយៈការពិភាក្សាជាក្រុម និងការបង្ហាញអំពីភាពខ្លាំង ឱកាស សេចក្ដីប្រាថ្នា និងលទ្ធផល (ការវិភាគ SOAR) ដើម្បីកែលម្អសម្រាប់ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។




*រូបភាពទី៥- សិក្ខាសាលាពិគ្រោះយោបល់ផែនការយុទ្ធសាស្ត្រសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*

## ២.៤ លទ្ធផលការងារក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ

### ២.៤.១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស

ក្នុងឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាលបានចំនួន ៤លើក ដោយផ្តោតទៅលើប្រធានបទសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំសន្និបាតលើកទី១២ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤
- ការរៀបចំសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥ នៅថ្ងៃទី៣-៤ ខែធ្នូ ឆ្នាំ២០២៤
- ការចុះអនុស្សរណៈយោគយល់គ្នារវាង សមាគម CWA និង សមាគម KOWBA និងសមាគម AWA
- សមិទ្ធផលស្នាដៃសំខាន់ៗរបស់ក្រុមប្រឹក្សាភិបាល អាណត្តិទី១ និងការរៀបចំព្រាងលិខិតស្នើសុំកិច្ចអន្តរាគមន៍ក្នុងការអនុគ្រោះលើកលែងពន្ធសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។



*រូបភាពទី៦- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសនៅការិយាល័យសមាគម*

## ២.៤.២ កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលតាមអនឡាញ និងប្រជុំផ្ទាល់ចំនួន ៥លើក ដូចខាងក្រោម៖

- **លើកទី១៖** ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ប្រជុំក្រុមប្រឹក្សាភិបាល ស្តីពីការបញ្ឈប់សមាជិកភាព។ ជាលទ្ធផលអង្គប្រជុំបានឯកភាពជាឯកច្ឆន្ទ (៩សំឡេងលើ ៩សំឡេង) ក្នុងការបញ្ចប់សមាជិកចំនួន ១៣ស្ថានីយ។
- **លើកទី២៖** ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៤ ប្រជុំក្រុមប្រឹក្សាភិបាលលើកទី១ សម្រាប់សមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី២។ កិច្ចប្រជុំផ្តោតលើការជ្រើសរើស ហេរញ្ញិក និងជ្រើសតាំងសមាជិកក្រុមប្រឹក្សាភិបាលថ្មី ១នាក់ជំនួស **លោក ហម ងួន** ដែលបានសុំលាឈប់។ ជាលទ្ធផល **លោក សៀ សេងហ៊ាប** ត្រូវបានជ្រើសរើសជា**ហេរញ្ញិក** និង **លោក ហៀក អេងឡាយ** ជាសមាជិកក្រុមប្រឹក្សាភិបាលជំនួស **លោក ហម ងួន**។ ជំហានបន្ទាប់សមាគមត្រូវរៀបចំឯកសារស្នើទៅក្រសួងមហាផ្ទៃសុំទទួលស្គាល់សមាសភាពថ្មីនៃរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី២សម្រាប់នីតិបុគ្គល ក្នុងអំឡុងពេល១៥ថ្ងៃនៃថ្ងៃធ្វើការក្រោយពីសន្និបាត កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤។ ជាលទ្ធផលក្រសួងមហាផ្ទៃបានចេញលិខិតលេខ៖ ១២១២ សជណ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ទទួលស្គាល់សមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី២ ឆ្នាំ២០២៤-២០២៧។
- **លើកទី៣៖** ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានសម្រេចជាឯកច្ឆន្ទអំពី«**គោលនយោបាយគាំទ្រប្រាក់ចុះបេសកកម្មការងារ និងចូលរួមប្រជុំតាមខេត្តរបស់ក្រុមប្រឹក្សាភិបាល**» ព្រមទាំងបានធ្វើបច្ចុប្បន្នភាពអំពីអាសយដ្ឋានរបស់ក្រុមប្រឹក្សាភិបាល។
- **លើកទី៤៖** ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានពិភាក្សាអំពី៖
  ១) អង្គប្រជុំបានសម្រេចឱ្យសមាគមរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ជាមួយសមាជិក ដោយចាត់តាំង **លោក ចាន់ ថានី** សមាជិកក្រុមប្រឹក្សាភិបាល និងម្ចាស់ស្ថានីយទឹកស្អាតបហ៊ុយ ក្នុងចែករំលែកបទពិសោធន៍អំពីក្រុមការងារចុះពិនិត្យ និងវាយតម្លៃស្ថានភាពជាក់ស្តែងរបស់ប្រតិបត្តិករផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតឯកជន ដើម្បីឱ្យសមាជិកទទួលបានជាព័ត៌មាន និងជាសារសម្រាប់ប្រតិបត្តិករទាំងអស់ត្រៀមខ្លួនជាមុន។
  ២) ការចូលរួមពិធីប្រកាសសមាសភាពប្រធានក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រដ្ឋាករទឹកស្ទឹងត្រែង រដ្ឋាករទឹកបាត់ដំបង រដ្ឋាករទឹកពោធិ៍សាត់ រដ្ឋាករទឹកកំពត និងរដ្ឋាករទឹកក្រុងស្ទឹងសែន នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។ អង្គប្រជុំសម្រេចឱ្យក្រុមប្រឹក្សាភិបាលទាំង ៩រូប និងនាយកប្រតិបត្តិទៅចូលរួមកម្មវិធី។
- **លើកទី៥៖** ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ អង្គប្រជុំបានឯកភាពជាឯកច្ឆន្ទ (៩សំឡេងលើ ៩សំឡេង) ក្នុងការកែសម្រួលប្រាក់វិភាគទានសមាជិកភាពប្រចាំឆ្នាំដូចខាងក្រោម៖

*តារាងទី២ - តារាងប្រាក់វិភាគទាន*

| ប្រភេទសមាជិក | តារាងប្រាក់វិភាគទានចាស់ | | តារាងប្រាក់វិភាគទានថ្មី | |
|---|---|---|---|---|
| | ចំនួនតំណ | ចំនួនប្រាក់វិភាគទាន | ចំនួនតំណ | ចំនួនប្រាក់វិភាគទាន |
| | ពី០ ដល់ ៧៥០តំណ | $២០០ | ពី០ ដល់ ៧៥០តំណ | $២០០ |
| | ពី៧៥១តំណ ដល់ ១៥០០ តំណ | $២៥០ | ពី៧៥១តំណ ដល់ ១៥០០តំណ | $២៥០ |

| ប្រភេទសមាជិក | តារាងប្រាក់វិភាគទានចាស់ | | តារាងប្រាក់វិភាគទានថ្មី | |
|---|---|---|---|---|
| | ចំនួនតំណ | ចំនួនប្រាក់វិភាគទាន | ចំនួនតំណ | ចំនួនប្រាក់វិភាគទាន |
| សមាជិកអាជីព | ពី១៥០១តំណ ដល់ ៣០០០ តំណ | $៣៥០ | ពី១៥០១តំណ ដល់ ៣០០០តំណ | $៣៥០ |
| | ពី៣០០១តំណ ដល់ ៦០០០ តំណ | $៥០០ | ពី៣០០១តំណ ដល់ ៦០០០តំណ | $៥០០ |
| | ពី៦០០១ ឡើងទៅ | $៧០០ | **ពី៦០០១តំណ ដល់ ១០០០០តំណ** | **$៧០០** |
| | | | **ពី១០០០១តំណ ដល់ ១៥០០០តំណ** | **$១០០០** |
| | | | **ពី១៥០០១តំណ ដល់ ២០០០០តំណ** | **$១៥០០** |
| | | | **ពី២០០០១តំណ ដល់ ២៥០០០តំណ** | **$២០០០** |
| | | | **ពី២៥០០១តំណ ដល់ ៣០០០០តំណ** | **$២៥០០** |
| | | | **ពី៣០០០១តំណ ឡើងទៅ** | **$៣០០០** |
| សមាជិកគាំទ្រ | ជារូបវន្តបុគ្គល | $១០០ | ជារូបវន្តបុគ្គល | $១០០ |
| | ជារូបវន្តបុគ្គលដែលផ្តល់សេវា | $៣០០ | ជារូបវន្តបុគ្គលដែលផ្តល់សេវា | $៣០០ |
| | ជានិតីបុគ្គល(សញ្ជាតិខ្មែរ) | $២៥០ | ជានិតីបុគ្គល(សញ្ជាតិខ្មែរ) | $២៥០ |
| | ជានិតីបុគ្គល(សញ្ជាតិបរទេស) | $៣៥០ | ជានិតីបុគ្គលបរទេស(សញ្ជាតិបរទេស) | $៣៥០ |

### ២.៤.៣ កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៣

ថ្ងៃទី២៤-២៦ ខែមករា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងការងារប្រចាំឆ្នាំ ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល និងបុគ្គលិក នៅខេត្តកំពត។ ជាលទ្ធផល៖ ១).ឆ្លុះបញ្ចាំងលទ្ធផលការងារឆ្នាំ២០២៣ និងរៀបចំផែនការឆ្នាំ២០២៤ ២).បង្កើតជាវេទិកាមួយក្នុងការទទួលស្គាល់ការខិតខំរបស់បុគ្គលិកដែលបានប្តេជ្ញាចិត្ត និងការចូលរួមចំណែកឱ្យចក្ខុវិស័យ និងបេសកកម្មរបស់សមាគមទទួលបានជោគជ័យ ៣).បង្កើនទំនាក់ទំនងឱ្យកាន់តែប្រសើររវាងបុគ្គលិក និងក្រុមប្រឹក្សាភិបាល ៤).ពិភាក្សាអំពីការរៀបចំសន្និបាតលើកទី១២ ៥).វាយតម្លៃការងាររបស់សមាគមប្រចាំឆ្នាំ២០២៣ និង៦).ទស្សនកិច្ចសិក្សានៅរោងចក្រផលិតទឹកស្អាតម្លេចរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។



*រូបភាពទី៧- កិច្ចប្រជុំឆ្លុះបញ្ចាំងប្រចាំឆ្នាំ២០២៣*



*រូបភាពទី៨-ទស្សនកិច្ចសិក្សានៅរោងចក្រផលិតទឹកស្អាតម្លេច*

### ២.៤.៤ ការចូលជួបសម្តែងការគួរសម

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី២ ទាំង៩នាក់ (ស្រី ២នាក់) បានចូលជួបសម្តែងការគួរសម និងសុំអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.) សម្រាប់ជាចក្ខុវិស័យក្នុងការដឹកនាំសមាគមក្នុងអាណត្តិថ្មី ឱ្យទទួលបានជោគជ័យទៅតាមផែនការយុទ្ធសាស្ត្រ បេសកកម្ម និងទស្សនវិស័យរបស់សមាគម ពោលគឺផ្តល់ឱ្យប្រជាពលរដ្ឋកម្ពុជាទទួលបានទឹកស្អាតប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។



*រូបភាពទី៩- ការចូលជួបសម្តែងការគួរសមរបស់ក្រុមប្រឹក្សាភិបាលនៅទីស្តីការរបស់ក្រសួង ឧ.វ.ប.ន.*

ក្នុងជំនួបសម្តែងការគួរសមនេះ ក្រុមប្រឹក្សាភិបាលសមាគមបានស្នើសុំ **ឯកឧត្តមរដ្ឋមន្ត្រី** ដូចខាងក្រោម៖

១. ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលទទួលបានប្រកាសអនុញ្ញាត (អាជ្ញាបណ្ណ)ពី ក្រសួង ឧ.វ.ប.ន. ទាំងអស់ចូលជាសមាជិករបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។

២. ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនទទួលបានការលើកលែងពន្ធលើប្រាក់ចំណូល(ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ) ពន្ធអាករបន្ថែម(VAT ១០%)ទៅលើការភ្ជាប់សេវាអតិថិជន ប្រាក់រំដោះពន្ធលើប្រាក់ចំណូល (អត្រា ១%លើផលរបរប្រចាំខែ) ពន្ធអប្បរមា(អត្រា១% លើផលរបរប្រចាំឆ្នាំ)។

៣. សុំឱ្យមានយន្តការច្បាស់លាស់ក្នុងការដោះស្រាយការខូចខាតបំពង់ទឹកស្អាតដោយការឈូសឆាយផ្លូវថ្នល់ ពេលគឺសុំឱ្យមានសំណងសមរម្យលើការខូចខាតបំពង់ទឹកស្អាត។
៤. ជួយរកប្រភពហិរញ្ញប្បទានសម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។

# ៣. ការងារជាមួយសមាជិក

## ៣.១ អំពីសមាជិកភាព

ក្នុងឆ្នាំ២០២៤ សមាគមទទួលបានសមាជិកថ្មីចំនួន ១៨ស្ថានីយ/ក្រុមហ៊ុន ក្នុងនោះមាន ៩ស្ថានីយជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និង ៩ជាក្រុមហ៊ុន។ ទន្ទឹមនឹងនេះដែរក៏មានសមាជិកចំនួន ៣៧ស្ថានីយ/ក្រុមហ៊ុន ក្នុងនោះ បានលាឈប់ចំនួន ១៨ស្ថានីយ ក្រុមប្រឹក្សាភិបាលបញ្ចប់សមាជិកភាពចំនួន ១៥ស្ថានីយ និង ៤ក្រុមហ៊ុន។ នៅដំណាច់ឆ្នាំ២០២៤ សមាគមមានសមាជិកសរុបចំនួន ៣២២ស្ថានីយ/ក្រុមហ៊ុន ក្នុងនោះសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ២៧៦ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាត សរុបចំនួន ៤៦ក្រុមហ៊ុន បាន នឹងកំពុងប្រតិបត្តិការក្នុង ២៣រាជធានី/ខេត្ត/ក្រុងនៃព្រះរាជាណាចក្រកម្ពុជា។




*ក្រាហ្វិច១៖ ទិន្នន័យសមាជិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*

### ៣.១.១ ការចូលជាសមាជិកថ្មីរបស់សមាគម

ក្នុងឆ្នាំ២០២៤ សមាគមបានទទួលសមាជិកថ្មីដូចមានរាយនាមខាងក្រោម៖

*តារាងទី៣ - សមាជិកថ្មីឆ្នាំ២០២៤*

| សមាជិកអាជីព | សមាជិកគាំទ្រ |
|---|---|
| ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ថេបអេហ្វិក ឯ.ក | ១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សាមគ្គីមានជ័យ | ២. ក្រុមហ៊ុន ផាម អេឡិកទ្រិក ស៊ីលូសិន ឯ.ក |
| ៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំសាលាវិស័យ | ៣. ក្រុមហ៊ុន ជេអេចអេសវ៉ាយ (ខេមបូឌា) ផាយឡាញ ឯ.ក |
| ៤. ក្រុមហ៊ុន អេស៊ា ស្វាយរៀង វ៉ដើរ ឯ.ក | ៤. ក្រុមហ៊ុន អាយ.អេស.អ៊ី.អេ អេនជីនារីង ឯ.ក |
| ៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បឹងខ្នារ វង់ ធារី | ៥. ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា |

| សមាជិកអាជីព | សមាជិកគាំទ្រ |
|---|---|
| ៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រ៉ុមលីលី ទឹកជ្រៅ | ៦. Molecor South East Asia |
| ៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សន្តិភាព | ៧. ធនាគារប្រៃសណីយ៍កម្ពុជា ក.អ |
| ៨. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកកំពង់ពោធិ៍ | ៨. KLR Industries Limited |
| ៩. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្រពាំងក្រញូង | ៩. ក្រុមហ៊ុន អេ ធី អេស សូលូសិន ឯ.ក |

## ៣.១.២ ការបាត់បង់សមាជិកភាព

*តារាងទី៤ - សមាជិកអាជីពដែលបានបាត់បង់សមាជិកភាពក្នុងឆ្នាំ២០២៤*

| សមាជិកអាជីព | |
|---|---|
| ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដូនស | ១៨. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អន ដុំ |
| ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហេង សុខន | ១៩. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មុខកំពូល ឯ.ក |
| ៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពៅ វណ្ណចេ១ | ២០. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រៃយុថ្កា |
| ៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពៅ វណ្ណចេ២ | ២១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាយរាយណ៍ |
| ៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កញ្ចំ | ២២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដីភូ |
| ៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ថ្មស | ២៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត យុន ឡាំ |
| ៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហៃសិទ្ធិ គីមឡុង | ២៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ង៉ូវ ស៊ុទ្រី |
| ៨. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទូច លិន | ២៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្រែងត្រយឹង |
| ៩. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អ៊ីវ ដារ៉េដ | ២៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត យុន ណៃហៀក |
| ១០. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហេង លក្ស្មី | ២៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត យុន សុហ្គិច |
| ១១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំបូរណ៍ | ២៨. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្រពាំងផ្លុង |
| ១២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកអំបិលក្លាត | ២៩. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សោប |
| ១៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះអណ្តែត | ៣០. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំចន្ទ្រា ឈើតុំ |
| ១៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចាន់ ម៉ាឡា | ៣១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឈូក |
| ១៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពងទឹក | ៣២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទូក មាស |
| ១៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សុខ លាង | ៣៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ត្រាច |
| ១៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជប់ | |

*តារាងទី៥ - សមាជិកគាំទ្រដែលបានបាត់បង់សមាជិកភាពក្នុងឆ្នាំ២០២៤*

| សមាជិកគាំទ្រ | |
|---|---|
| ១. ថាយហ្គើរ វ៉ធើរ សឹលូសិន (ខេមបូឌា) ឯ.ក | ៣. ក្រុមហ៊ុន ខេមបូ- អេស៊ា ត្រេឌីង ខមភេនីលីមីធីត |
| ២. អង្គការ ទឹកស្អាត មួយពាន់មួយ | ៤. ក្រុមហ៊ុន គ័នហេង |

## ៣.២ កិច្ចប្រជុំថ្នាក់តំបន់

ក្នុងឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់បានចំនួន ៥លើក ក្នុងគោលបំណងដើម្បីៈ ១).បង្កើនទំនាក់ទំនងរវាងសមាជិក និងថ្នាក់ដឹកនាំសមាគម ក៏ដូចជារវាងសមាជិកនិងសមាជិក ២).ស្វែងយល់ពីការរីកចម្រើនបញ្ហាប្រឈម និងបង្កើតផែនការសកម្មភាពដើម្បីរកដំណោះស្រាយជូនសមាជិក ៣).បច្ចុប្បន្នភាពអំពីច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និង ៤).ចែករំលែកចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។

- **លើកទី១ៈ** ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ កិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករអញ្ជើញមកពីខេត្តព្រះវិហារ បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ធំ និងសៀមរាប។ កិច្ចប្រជុំបានប្រព្រឹត្តទៅនៅសណ្ឋាគារផាវ៉ាដាយ ក្រុងសៀមរាប ក្រោមអធិបតីភាព **លោក ជា វុធឡុង** ប្រធានមន្ទីរ ឧ.រ.ប.ន. ខេត្តសៀមរាប និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។



*រូបភាពទី១០- កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តសៀមរាប*

កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៧៧នាក់(ស្រី ១៦នាក់) រួមមានៈ ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ឧ.រ.ប.ន. ខេត្តសៀមរាប អង្គការ Water.org ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម តំណាងធនាគារ តំណាងក្រុមហ៊ុនទាំង៧ ព្រមទាំងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ២៨ស្ថានីយ។ កិច្ចប្រជុំថ្នាក់តំបន់ទទួលបានការឧបត្ថម្ភពីអង្គការ Water.org និងដៃគូសហការឧបត្ថម្ភៈ ១).ក្រុមហ៊ុន ធីស៊ីយូ T.C.U Polys Enterprise ២).ក្រុមហ៊ុនភ្នំពេញប្លាស្ទិច (PP Plastic Product) ៣).ក្រុមហ៊ុន LESSO Trading Cambodia ៤).ក្រុមហ៊ុន យូភីជីផាយ (UPG Pipe Co., Ltd) ៥).ក្រុមហ៊ុន អ៊ិចវ៉តធើ(X-Water Technology Co., Ltd) ៦).ក្រុមហ៊ុន ផាមអេឡិចទ្រិកសូលូសិន (Pump Electric Solution Co., LTD), និង ៧).ក្រុមហ៊ុន ឃិនតិច តិចណូឡូជី (KINTEK Technology Co., Ltd)។



*រូបភាពទី១១- បទបង្ហាញស្តីពីលទ្ធផលពិភាក្សាក្រុម*

❖ **លើកទី២៖** ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ កិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករជាសមាជិកសមាគម មកពីខេត្តព្រះវិហារ កំពង់ធំ ព្រៃវែង មណ្ឌលគីរី ក្រចេះ ត្បូងឃ្មុំ និងកំពង់ចាម។ កិច្ចប្រជុំនេះប្រព្រឹត្តទៅនៅសណ្ឋាគារភ្នំប្រុស ខេត្តកំពង់ចាម ក្រោមអធិបតីភាព **លោក ពូន រុន** ប្រធានមន្ទីរ ឧ.រ.ប.ន. ខេត្តកំពង់ចាម និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៧៩នាក់( ស្រី ១៧នាក់ ) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរ ឧ.រ.ប.ន. ខេត្តកំពង់ចាម អង្គការ Water.org ក្រុមប្រឹក្សាភិបាលបុគ្គលិកសមាគម តំណាងធនាគារ ក្រុមហ៊ុនទាំង ៦ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៤៤ស្ថានីយ។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភពីក្រុមហ៊ុនទាំង ៦ រួមមាន៖ ១ ).ក្រុមហ៊ុន TCU ២ ).ក្រុមហ៊ុន Phnom Penh Plastic ៣ ).ក្រុមហ៊ុន X-Water ៤ ).គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ៥ ).ក្រុមហ៊ុន UPG Pipe និង ៦ ).ក្រុមហ៊ុន LESSO Trading។



*រូបភាពទី១២- កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តកំពង់ចាម*

❖ **លើកទី៣៖** ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ កិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករជាសមាជិកសមាគម មកពីខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងឧត្តរមានជ័យ។ កិច្ចប្រជុំនេះប្រព្រឹត្តទៅនៅសណ្ឋាគារ ខេមរាបាត់ដំបង១ ខេត្តបាត់ដំបង ក្រោមអធិបតីភាព **លោក រស់ វិសិទ្ធ** អនុប្រធាន មន្ទីរ ឧ.វ.ប.ន. ខេត្តបាត់ដំបង និង **លោក ឡេង ឡៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៨៦នាក់(ស្រី ១៨នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរ ឧ.វ.ប.ន. ខេត្តបាត់ដំបង ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម តំណាងធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣៩ស្ថានីយ។ ក្នុងកិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីអង្គការ Water.org និងសហការឧបត្ថម្ភពី៖ ១).គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ២).ក្រុមហ៊ុន TCU ៣).ក្រុមហ៊ុន X-Water ៤).ក្រុមហ៊ុន KCRI ៥).ក្រុមហ៊ុន TECHZONE Plus ៦).ក្រុមហ៊ុន LESSO Trading និង ៧).ក្រុមហ៊ុន CHIP MONG។



*រូបភាពទី១៣- កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តបាត់ដំបង*

នៅរសៀលថ្ងៃដដែល សមាគមបានសម្របសម្រួលសមាជិកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់ក្នុងខេត្តបាត់ដំបងទៅទស្សនកិច្ចសិក្សាស្វែងយល់ពីការគ្រប់គ្រងអាជីវកម្ម និងបច្ចេកទេសផលិតទឹកស្អាតនៅរដ្ឋាករទឹកបាត់ដំបង។



*រូបភាពទី១៤- ទស្សនកិច្ចសិក្សាទៅកាន់រោងចក្រផលិតទឹកស្អាតនៃរដ្ឋាករទឹកបាត់ដំបង(ការលាងអាងខ្សាច់)*



*រូបភាពទី១៥- សិក្ខាកាមបានចូលរួមស្តាប់បទបង្ហាញរបស់តំណាងរដ្ឋាករទឹកបាត់ដំបង*

- **លើកទី៤៖** ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ កិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករអញ្ជើញមកពីខេត្តកំពង់ស្ពឺ តាកែវ កែប កំពត ព្រះសីហនុ និងខេត្តកោះកុង។ កិច្ចប្រជុំប្រព្រឹត្តទៅនៅរមណីយដ្ឋានភូមិសេរីមង្គល ខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាព **លោក នួន សុភណ្ឌ** ប្រធានមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ស្ពឺ និង **លោក ឡេង ឌៀវ** ប្រធានក្រុមប្រឹក្សាភិបាល។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ១០៣នាក់ (ស្រី ២០នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ស្ពឺ អង្គការ Water.org ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK និងក្រុមហ៊ុនរួមមាន៖ ១).ក្រុមហ៊ុន TCU ២).ក្រុមហ៊ុន X-Water ៣).ក្រុមហ៊ុន UPG Pipe ៤).ក្រុមហ៊ុន MK Waterware ៥).ក្រុមហ៊ុន LESSO ៦).ក្រុមហ៊ុន CHIP MONG ៧).ក្រុមហ៊ុន LEO Pump Cambodia និង ៨).ក្រុមហ៊ុន AMO។



*រូបភាពទី១៦- កិច្ចប្រជុំថ្នាក់តំបន់នៅខេត្តកំពង់ស្ពឺ*

❖ **លើកទី៥៖** ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ កិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករអញ្ជើញមកពីភ្នំពេញ ខេត្តកណ្ដាល ព្រៃវែង ស្វាយរៀង និងប្រតិបត្តិករដែលមិនទាន់បានចូលរួមកិច្ចប្រជុំថ្នាក់តំបន់នាពេលកន្លងមក។ កិច្ចប្រជុំរៀបចំនៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ ក្រោមអធិបតីភាព **លោក ហួត វណ្ណថូ** ប្រធានមន្ទីរ ឧ.វ.ប.ន. ខេត្តកណ្ដាល និង **លោក ឡេង ឌៀវ** ប្រធានក្រុមប្រឹក្សាភិបាល។ សមាសភាពអ្នកចូលរួមសរុបចំនួន ៩៥នាក់ (ស្រី ១៦នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរ ឧ.វ.ប.ន. ខេត្តកណ្ដាល អង្គការ Water.org ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម តំណាងក្រុមហ៊ុន ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភ ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ និងក្រុមហ៊ុនរួមមាន៖ ១).គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ២).ក្រុមហ៊ុន TCU ៣).ក្រុមហ៊ុន X-Water ៤).ក្រុមហ៊ុន LEO Pump ៥).ក្រុមហ៊ុន CHIP MONG Cambodia និង ៦).ធនាគារ FTB។




*រូបភាពទី១៧- កិច្ចប្រជុំថ្នាក់តំបន់នៅ រាជធានីភ្នំពេញ*

## ៣.៣ កិច្ចគាំពារសមាជិក

### ៣.៣.១ បញ្ហាខូចខាតបណ្ដាញបំពង់ទឹកស្អាត

សមាគមបានគាំទ្រ និងសម្របសម្រួលកិច្ចប្រជុំដោះស្រាយបញ្ហារបស់សមាជិកបានចំនួន ៣ករណី៖

១. **ករណីទី១៖** ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ ថ្នាក់ដឹកនាំសមាគមបានជួបប្រជុំជាមួយ **លោក យឹម សំអឿន** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំព្រែករំដេង ដើម្បីពិគ្រោះយោបល់ និងពិភាក្សាលើបញ្ហាក្រុមហ៊ុនឈូសឆាយផ្លូវធ្វើឱ្យខូចខាតប្រព័ន្ធបណ្ដាញបំពង់ទឹកស្អាតរបស់ស្ថានីយ។ ក្នុងកំឡុងពេលនៃកិច្ចពិភាក្សា សមាគមបានជូនជាមតិយោបល់ដែលទាក់ទងទៅនឹងអង្គហេតុ ព្រមទាំងបានស្នើឱ្យ **លោក យឹម សំអឿន** ប្រមូលនូវឯកសារព្រមទាំងភស្តុតាងនានា ដើម្បីដាក់ជូនទៅអាជ្ញាធរឃុំ ស្រុក មន្ទីរ និងក្រសួង ឧ.វ.ប.ន. ដើម្បីជួយដោះស្រាយនូវបញ្ហានេះ។ ជាលទ្ធផល សមាគមបានជួយរៀបចំឯកសារជូនស្ថានីយផ្គត់ផ្គង់ទឹកស្អាតឃុំព្រែករំដេង សម្រាប់ដាក់ជូនទៅក្រសួង ឧ.វ.ប.ន.។



*រូបភាពទី១៨- សកម្មភាពឈូសឆាយរបស់ក្រុមហ៊ុនដែលបណ្ដាលឱ្យប៉ះពាល់ដល់បណ្ដាញបំពង់ទឹកស្អាត*

២. **ករណីទី២៖** នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានដឹកនាំសមាជិកចំនួន ២៤នាក់/ស្ថានីយ ចូលរួមកិច្ចប្រជុំដោះស្រាយទំនាស់នៃការខូចខាតបំពង់ទឹកស្អាតដោយសារការស្ថាបនាផ្លូវ( ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រពុំឈូក)។ កិច្ចប្រជុំនេះសម្របសម្រួលដោយ លោកអភិបាលនៃគណៈអភិបាលស្រុកកោះអណ្ដែត និងមានការចូលរួមពីប្រធានមន្ទីរ ឧ.វ.ប.ន. និងមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តតាកែវ អាជ្ញាធរឃុំ និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ ជាលទ្ធផល ភាគីទាំងសងខាងបានឯកភាពគ្នាទទួលយកដំណោះស្រាយឈ្នះៗ ដោយព្រមព្រៀងគ្នាបង្កើត គណៈកម្មការចុះវាស់វែងការខូចខាតបំពង់ទឹកស្អាត និងសងថ្លៃផលប៉ះពាល់បណ្ដាញទៅដល់ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រពុំឈូកចំនួន ៥០ភាគរយ។ ក្នុងនោះដែរ សមាគមបានចាត់បញ្ជូនវិស្វករបច្ចេកទេសទឹកស្អាតជាន់ខ្ពស់ ទៅចូលរួមក្នុងគណៈកម្មការវាស់វែង នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤។



*រូបភាពទី១៩- កិច្ចប្រជុំដោះស្រាយទំនាស់នៃការខូចខាតបំពង់ទឹកស្អាតដោយសារការស្ថាបនាផ្លូវ*

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៤ វិស្វករបច្ចេកទេសទឹកស្អាតជាន់ខ្ពស់ សមាគមបានសហការជាមួយ **លោក លី ស៊ីដា** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រពុំឈូក មេឃុំ ក្រុមប្រឹក្សាឃុំក្រពុំឈូក និងបុគ្គលិករបស់ក្រុមហ៊ុនស្ថាបនាផ្លូវ ក្នុងការវាស់វែងពីផលប៉ះពាល់នៃបណ្ដាញទឹកស្អាត ដែលរងការខូចខាត។



*រូបភាពទី២០- ការវាស់វែងពីផលប៉ះពាល់នៃបណ្តាញទឹកស្អាត ដែលរងការខូចខាត*

៣. **ករណីទី៣៖** នៅរសៀលថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានដឹកនាំសមាជិករបស់ខ្លួនចំនួន ២៥នាក់ ដើម្បីចូលរួមដោះស្រាយបញ្ហាខូចខាតបំពង់ទឹកស្អាតដែលបណ្តាលមកពីក្រុមហ៊ុនធ្វើផ្លូវក្នុងឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល។ កិច្ចប្រជុំនេះសម្របសម្រួលដោយ លោកអភិបាលរងស្រុក និងមេឃុំពោធិបាន។ ជាលទ្ធផល ក្រុមហ៊ុនធ្វើផ្លូវសងសំណងដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពោធិបាន ប្រមាណ ៥៧%នៃថ្លៃខូចខាត និងយល់ព្រមសហការជាមួយស្ថានីយទឹកស្អាត ដើម្បីបញ្ចៀសការខូចខាតបំពង់ទឹកស្អាតជាអប្បបរមានាពេលខាងមុខ។ កិច្ចប្រជុំរៀបចំឡើងនៅសាលាឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល។




*រូបភាពទី២១- កិច្ចប្រជុំដោះស្រាយទំនាស់នៃការខូចខាតបំពង់ទឹកស្អាតដោយសារការស្ថាបនាផ្លូវ*

## ៣.៣.២ ការសម្របសម្រួល និងដោះស្រាយបញ្ហាប្រភពទឹក

ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤ សមាគមបានសហការជាមួយ មន្ទីរ ឧ.រ.ប.ន. ខេត្តតាកែវ និងអាជ្ញាធរ មូលដ្ឋាន ប្រជុំដោះស្រាយទំនាស់នៃការបូមទឹកបឹងអំពែទុំ។ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់បានស្នើសុំបូមទឹកបឹងអំពែទុំសម្រាប់ផលិតទឹកស្អាត ដើម្បីផ្គត់ផ្គង់នៅក្នុងសហគមន៍ឃុំលំពង់។ ចំណែកប្រជាពលរដ្ឋចំនួន ៤៨គ្រួសារ នៅភូមិអំពែទុំ ភូមិរវៀង និងភូមិអង្គក្រឡាញ់ នៃឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ ដែលជាអ្នកយកទឹកបឹងអំពែទុំមកធ្វើស្រែប្រាំង។

ជាលទ្ធផលភាគីទាំងអស់បានឯកភាពគ្នាទៅលើ ៣ចំណុចៈ ១).អនុញ្ញាតឱ្យស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់បូមទឹកជម្រៅមួយម៉ែត្រនៃផ្ទៃទឹកបឹង ២).បើដល់កម្រិតកម្ពស់ទឹកនៅសល់ត្រឹមមួយម៉ែត្រ និងពេលមានភ្លៀងធ្លាក់គ្រប់គ្រាន់ម្ចាស់ស្ថានីយត្រូវរើម៉ូទ័រ និងទុយោចេញពីបឹង និង ៣).ស្នើសុំស្ថានីយជួយផ្តល់ថវិកាចំនួន ៣លានរៀលក្នុងមួយភូមិសម្រាប់ការងារអភិវឌ្ឍន៍នៅក្នុងភូមិ។ ក្រោយដំណោះស្រាយ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់បានបូមទឹកផៅពីបឹងអំពៃទុំដើម្បីយកមកផលិតទឹកស្អាតសម្រាប់ផ្គត់ផ្គង់នៅក្នុងសហគមន៍ឃុំលំពង់រួចរាល់ហើយ។



*រូបភាពទី២២- ទិដ្ឋភាពនៃការបូមទឹកផៅពីបឹងអំពៃទុំ របស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់*

## ៣.៤. កិច្ចគាំទ្រជំនួយផ្នែកបច្ចេកទេស

### ៣.៤.១ ការធ្វើជាងរតេស្ត និងវិភាគគុណភាពទឹក

ដើម្បីបង្កើនគុណភាពទឹកស្អាតរបស់សមាជិក សមាគមបានទទួលធ្វើជាងរតេស្ត និងវិភាគគុណភាពទឹក ជូនប្រតិបត្តិករជាសមាជិក ព្រមទាំងបានផ្តល់ប្រឹក្សាយោបល់លើបច្ចេកទេសផលិតទឹកស្អាត ការត្រួតពិនិត្យគុណភាពទឹកជូនដល់ប្រតិបត្តិករ ដូចខាងក្រោមៈ

*តារាងទី ៦- បញ្ជីឈ្មោះស្ថានីយដែលបានធ្វើជាងរតេស្ត និងវិភាគគុណភាពទឹកនៅសមាគម*

| ឈ្មោះស្ថានីយ | |
|---|---|
| ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំចាយមារ | ៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត តាំងក្រសាំង |
| ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ផ្សារស្លាបលែង | ៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កែវសីមា |
| ៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហ៊ឹង ហុង | ៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រៃប្រស់ |
| ៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដំរីផុង | ៨. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត លំពង់ |
| ៩. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីន ពេជសារ | ១៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រពុំឈូក |
| ១០. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បុរីជលសារ | ១៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភូមិយើង |
| ១១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជា សារឿន | ១៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះអណ្តែត |
| ១២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រលាំងចក | ១៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទំនប់ជើងព្រៃ |



*រូបភាពទី២៣- ការធ្វើតេស្តគុណភាពទឹកទៅ ជូន លោក សួស ពុយ ម្ចាស់ស្ថានីយទឹកស្អាត ស្លាបលែង*



*រូបភាពទី២៤- បុគ្គលិកសមាគមបង្ហឹកផ្ទាល់លើការអនុវត្តការវិភាគគុណភាពទឹកស្អាតលើ ៥ប៉ារ៉ាម៉ែត្រ ប្រចាំថ្ងៃ*

## ៣.៤.២ កម្មវិធីកសាងសមត្ថភាព

សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលជូនដល់សមាជិក បានចំនួន ៤វគ្គ រួមមាន៖

- **វគ្គទី១៖** នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«**ការគ្រប់គ្រងទឹកបាត់បង់ និងបច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**» នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ មានអ្នកចូលរួមសរុបចំនួន ៤៥នាក់ (ស្រី ៦នាក់)។ គោលបំណងនៃវគ្គបណ្តុះបណ្តាលរួមមាន៖
  ១) ពន្យល់បានពីបច្ចេកទេសនៃការសម្អាតទឹកចាប់ពីប្រភពទឹករហូតដល់អ្នកប្រើប្រាស់
  ២) រៀបរាប់បានពីបច្ចេកទេសសម្រាប់ប្រតិបត្តិការ និងការថែទាំ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និង
  ៣) កំណត់បានពីបច្ចេកទេសគ្រប់គ្រងទឹកបាត់បង់ សម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី២៥-រូបថតអនុស្សាវរីយ៍សម្រាប់ក្រុមទី១*

❖ **វគ្គទី២៖** នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«**ការគ្រប់គ្រងទឹកបាត់បង់ និងបច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**» នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ មានអ្នកចូលរួមសរុបចំនួន ៤០នាក់ (ស្រី ៨នាក់)។



*រូបភាពទី២៦-រូបថតអនុស្សាវរីយ៍សម្រាប់ក្រុមទី២*

❖ **វគ្គទី៣៖** នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«**វិធីសាស្ត្រធ្វើជ្សារតេស្ត និងការវិភាគគុណភាពទឹកស្អាត**»។ វគ្គបណ្តុះបណ្តាលនេះរៀនទ្រឹស្តីនៅក្នុងសណ្ឋាគារសាន់វេ និងអនុវត្តផ្ទាល់នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតបែកចាន។ វគ្គបណ្តុះបណ្តាលនេះមានអ្នកចូលរួមសរុបចំនួន ១៨នាក់(ស្រី ១នាក់)។

ជាលទ្ធផលនៃវគ្គបណ្តុះបណ្តាលនេះ អ្នកចូលរួមអាច ១).រៀបរាប់បានពីដំណើរការធ្វើជ្សារតេស្ត និងការវិភាគគុណភាពទឹកស្អាត ២).រៀបរាប់បានពីប៉ារ៉ាម៉ែត្រប្រចាំថ្ងៃ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ៣).រៀបរាប់បានពីផលប៉ះពាល់សារធាតុគីមីដែលមានក្នុងទឹក ៤).អនុវត្តការធ្វើជ្សារតេស្ត និងតេស្តគុណភាពទឹកស្អាត ៥).ទស្សនាប្រព័ន្ធសម្អាតទឹករបស់ស្ថានីយទឹកស្អាតបែកចាន និង ៦).ការចែករំលែកបទពិសោធន៍ល្អពីគ្នាទៅវិញទៅមក។



រូបភាពទី២៧- សកម្មភាពពិភាក្សាក្រុម



រូបភាពទី២៨- សកម្មភាពអនុវត្តការតេស្តគុណភាពទឹកស្អាតនៅស្ថានីយទឹកស្អាតបែកចាន



រូបភាពទី២៩- រូបថតអនុស្សាវរីយ៍នៅស្ថានីយទឹកស្អាតបែកចាន

- **វគ្គទី៤៖** នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ វគ្គបណ្តុះបណ្តាលស្តីពី«**ការសន្សំសំចៃថាមពល សម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជន**» ដែលមានអ្នកចូលរួមសរុបចំនួន ២២នាក់(ស្រី ៤នាក់) ក្នុងនោះមាន ១៥ស្ថានីយ និង ១ក្រុមហ៊ុន។ ក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាលសិក្ខាកាមមានលទ្ធភាព៖
  ១) កំណត់បានពីប៉ារ៉ាម៉ែត្រសំខាន់ៗ សម្រាប់ជ្រើសរើសម៉ាស៊ីនបូមទឹក
  ២) កំណត់បានពីការប្រើប្រាស់ប្រព័ន្ធសូឡាសម្រាប់ស្ថានីយ
  ៣) កំណត់បានពីអត្ថប្រយោជន៍នៃការប្រើប្រាស់ថាមពលអគ្គិសនី។



*រូបភាពទី៣០- ការចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា*

## ៣.៥ ការចុះសួរសុខទុក្ខសមាជិក

ដើម្បីស្វែងយល់អំពីសុខទុក្ខរបស់សមាជិក ដំណើរអាជីវកម្ម ស្តាប់អំពីបញ្ហាក៏ដូចជាសំណូមរបស់សមាជិក ដើម្បីយកមកពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក៏ដូចជាដើម្បីបង្កើនទំនាក់ទំនងល្អបន្ថែម បុគ្គលិកសមាគមបានចុះសួរសុខទុក្ខសមាជិកដល់ទីតាំងមួយចំនួនដូចខាងក្រោម៖

*តារាងទី ៧- បញ្ជីឈ្មោះស្ថានីយដែលសមាគមបានចុះសួរសុខទុក្ខ*

| ឈ្មោះស្ថានីយ | |
|---|---|
| ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំកោះមិត្ត | ១០. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំចាយមារ |
| ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អូរតាគន់ | ១១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រលាំងចក |
| ៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះអណ្តែត | ១២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភូមិយើងឃុំលើកដែក |
| ៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រពុំឈូក | ១៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត វុទ្ធាទឹកស្អាត ខេត្តកំពង់ចាម |
| ៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំរោង | ១៤. ក្រុមហ៊ុន L.A.A INVESTMENT CO,. LTD |
| ៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ជា សារឿន | ១៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រ៉ាត ណារុណ |
| ៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំព្នៅ | ១៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទឹកថា |
| ៨. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉ោ ចាន់ថា | ១៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំទន្លេបិទ |
| ៩. ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត ស្រុកមង្គលបុរី | |



*រូបភាពទី៣១- ការធ្វើជ្យារតេស្តទឹកឆៅ ដើម្បីកំណត់បរិមាណសារជាតុគីមីឱ្យបានត្រឹមត្រូវ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំចាយមារ*



*រូបភាពទី៣២- ការចុះសួរសុខទុក្ខសមាជិក នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតអូរតាគន់ ខេត្តបាត់តំបង*



*រូបភាពទី៣៣- បុគ្គលិកសមាគមចុះសួរសុខទុក្ខ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស( ទឹកស្អាតទ្រាំង )*

## ៣.៦ កម្មវិធីផ្សព្វផ្សាយអំពីសេវាកម្មទឹកស្អាតរបស់សមាជិក

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានដឹកនាំសមាជិកចូលរួមក្នុងកម្មវិធីសំណេះសំណាល និងបង្ហាញផែនការពង្រីកបណ្ដាញទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែករាំងដែលមានទីតាំងនៅភូមិព្រែករាំង ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ សមាសភាពអ្នកចូលរួមអញ្ជើញមកពី ១).តំណាងមន្ទីរឧ.វ.ប.ន. ខេត្តកំពង់ឆ្នាំង ២).ក្រុមប្រឹក្សាឃុំ និងមេភូមិ ៣).ប៉ុស្តិ៍ប៉ូលីស ៤).មណ្ឌលសុខភាព ៥).សាលារៀន ៦).សហគមន៍ ៧).ប្រតិបត្តករផ្គត់ផ្គង់ទឹកស្អាតឯកជន និង ៨).សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ កិច្ចប្រជុំមានគោលបំណងដូចខាងក្រោម៖

១. បង្ហាញអំពីវឌ្ឍនភាពនៃអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងផែនការពង្រីកបណ្ដាញថ្មី
២. បង្កើនទំនាក់ទំនង និងកិច្ចសហការល្អជាមួយអាជ្ញាធរគ្រប់លំដាប់ និងអតិថិជន
៣. ថ្លែងអំណរគុណអាជ្ញាធរគ្រប់លំដាប់ និងអតិថិជនដែលបានគាំទ្រដល់ស្ថានីយ
៤. បង្កើនការយល់ដឹងបន្ថែមអំពីសេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែករាំង។




*រូបភាពទី៣៤៖ កម្មវិធីសំណេះសំណាល និងបង្ហាញផែនការពង្រីកបណ្ដាញទឹកស្អាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែករាំង*

## ៣.៧ ដំណើរកម្សាន្ត និងទស្សនសិក្សារបស់សមាជិក

### ៣.៧.១ ដំណើរកម្សាន្ត និងទស្សនកិច្ចសិក្សាក្នុងប្រទេស

ក្នុងឆ្នាំ២០២៤ សមាគមបានរៀបចំដំណើរកម្សាន្ត និងទស្សនកិច្ចសិក្សាក្នុងប្រទេសសម្រាប់សមាជិកបានចំនួន ៥លើកមានដូចខាងក្រោម៖

- **លើកទី១៖** ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ សមាគមបានរៀបចំទស្សនកិច្ចសិក្សាទៅកាន់**ក្រុមហ៊ុន ខោលបុល ទឹកស្អាត ឯ.ក** និង**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ-រោងចក្រផលិតទឹកស្អាតម្លេច** ដើម្បីសិក្សារៀនសូត្រពីរបៀបនៃការរៀបចំស្ថានីយបូមទឹកឆៅ អាងប្រព្រឹត្តកម្មដោយស្វ័យប្រវត្តិ របៀបរៀបចំបន្ទប់ពិសោធន៍សម្រាប់វិភាគគុណភាពទឹកស្អាត និងប្រព័ន្ធទូបញ្ជាម៉ូទ័រ និងការគ្រប់គ្រងអាជីវកម្មដែលមានលក្ខណៈជាក្រុមហ៊ុន។ ជាងនេះទៅទៀត បានកសាងទំនាក់ទំនងល្អរវាងសមាជិក និងសមាគម ព្រមទាំងទទួលបាននូវអារម្មណ៍ស្រស់ថ្លាជាមួយរមណីយដ្ឋានធម្មជាតិម្លេចផងដែរ។ ដំណើរទស្សនកិច្ចសិក្សានេះមានអ្នកចូលរួមចំនួន ២៥នាក់ (ស្រី ៤នាក់) មកពី ១៤ស្ថានីយ និង ៥ក្រុមហ៊ុន។



*រូបភាពទី៣៥- ទស្សនកិច្ចសិក្សានៅក្រុមហ៊ុន ខោល បុល ទឹកស្អាត*



*រូបភាពទី៣៦- ទស្សនកិច្ចសិក្សានៅអាងប្រព្រឹត្តកម្ម រោងចក្រផលិតទឹកស្វយ័តក្រុងភ្នំពេញ-រោងចក្រផលិតទឹកស្អាតម្លេច*

- **លើកទី២៖** ថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤ សមាគមបានរៀបចំទស្សនកិច្ចសិក្សាទៅកាន់**ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពកត្របែក** និង**រោងចក្រទឹកកំពត** ដើម្បីសិក្សាស្វែងយល់ពី ចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាត ការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ស្វែងយល់បន្ថែមអំពីចង្វាក់ផលិតកម្ម បច្ចេកវិទ្យាថ្មីៗ ព្រមទាំងការរៀបចំស្ថានីយបូមទឹកឆៅ ដើម្បីយកទៅកែលម្អ និងអភិវឌ្ឍនៅស្ថានីយរៀងៗខ្លួន។ ក្នុងទស្សនកិច្ចសិក្សា និងដំណើរកំសាន្តនេះ មានសមាជិកចូលរួមចំនួន ១៤នាក់(ស្រី ៣នាក់) មកពី ១១ស្ថានីយ និង ២ក្រុមហ៊ុន។




*រូបភាពទី៣៧- ទស្សនកិច្ចសិក្សានៅស្ថានីយទឹកស្អាត ពកត្របែក*



*រូបភាពទី៣៨-រូបភាពនៅក្នុងបន្ទប់ពិសោធន៍ រោងចក្រទឹកស្អាត កំពត*

❖ **លើកទី៣៖** ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ សមាគមបានរៀបចំទស្សនកិច្ចសិក្សាទៅកាន់ **ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បហ៊ុយ** ដើម្បីសិក្សាស្វែងយល់ពី ចង្វាក់ផលិតកម្ម ការផ្គត់ផ្គង់ទឹកស្អាត និងការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ព្រមទាំងស្វែងយល់បន្ថែមអំពី នវានុវត្តន៍ និងបច្ចេកវិទ្យាថ្មីៗ ដែលស្ថានីយបហ៊ុយ បានរៀបចំដូចជា៖ ការរៀបចំស្ថានីយបូមទឹកផៅ និងការដំឡើងរហាត់ទឹកដើម្បីបង្កើតចរន្តអគ្គិសនីយកមកប្រើប្រាស់។ នៅក្នុងទស្សនកិច្ចសិក្សានេះមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិក និងសមាជិកសមាគមចំនួន ១៨នាក់ (ស្រី ៦នាក់) មកពី ៩ស្ថានីយ។



*រូបភាពទី៣៩- រហាត់ទឹកបង្កើតចរន្តអគ្គិសនី និងរោងចក្រផលិតទឹកស្អាត បហ៊ុយ*

- **លើកទី៤៖** ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៥ សមាគមបានដឹកនាំគណៈប្រតិភូមកពីប្រទេសម៉ាឡេស៊ី សឹង្ហបុរី សមាជិកសមាគម និងមន្ត្រីនៃក្រសួងសាធារណការ និងដឹកជញ្ជូន ទៅទស្សនកិច្ចសិក្សាស្វែងយល់អំពីចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាតរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅរោងចក្រផលិតទឹកស្អាត បាក់ខែង ដែលមានអ្នកចូលរួមសរុប ៤៦នាក់ (ស្រី១១នាក់)។



*រូបភាពទី៤០- ទស្សនកិច្ចសិក្សានៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ-រោងចក្រផលិតទឹកស្អាត បាក់ខែង*

- **លើកទី៥៖** ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានសហការជាមួយ **ស្ថានីយផលិតទឹកស្អាតស្វាយរមៀត** ក្នុងការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលមានទីតាំងស្ថិតនៅភូមិព្រៃកតាបែន ឃុំស្វាយរមៀត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ជូនដល់គណៈប្រតិភូអញ្ជើញមកពី សមាគមទឹកអូស្ត្រាលី (AWA) សមាជិកជាប្រតិបត្តិករ និងក្រុមហ៊ុន កម្មវិធី CAPRED ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម និងមានការចូលរួមពីអាជ្ញាធរឃុំផងដែរ។ សកម្មភាពនៅក្នុងទស្សនកិច្ចសិក្សារួមមាន៖

  ១. បទបង្ហាញអំពីស្ថានីយទឹកស្អាតស្វាយរមៀត (ប្រវត្តិ រចនាសម្ព័ន្ធ ការគ្រប់គ្រងអាជីវកម្ម ការគ្រប់គ្រងផ្នែកផលិត និងយុទ្ធសាស្ត្រធ្វើទីផ្សារ)

២. ការទស្សនាអំពីប្រព័ន្ធសម្អាតទឹករបស់ស្ថានីយ ចាប់ពីប្រភពទឹករហូតដល់អ្នកប្រើប្រាស់ (១.ប្រភពទឹក ២. ប្រពន្ធ័សម្អាតទឹក (ប្រព័ន្ធលាយ និងចាក់បញ្ចូលសារធាតុគីមី អាងពង្រងកករ អាងច្រោះ) ៣.អាងស្តុកទឹក ៤.ប្រព័ន្ធបញ្ជូន និងចែកចាយទឹកស្អាត ៥.បន្ទប់ពិសោធន៍ និងការិយាល័យ)។



*រូបភាពទី៤១- ទស្សនកិច្ចសិក្សានៅស្ថានីយផលិតទឹកស្អាតស្វាយរមៀត ខេត្តកណ្តាល*



*រូបភាពទី៤២- ការទស្សនាអាងប្រព្រឹត្តកម្មទឹកស្អាត*

## ៣.៧.២ ដំណើរកម្សាន្តក្រៅប្រទេស

ក្នុងឆ្នាំ២០២៤ សមាគមបានរៀបចំដំណើរកម្សាន្ត ជូនសមាជិកសមាគម ដោយបានទៅទស្សនា កោះត្រល់ ប្រទេសវៀតណាមចំនួន ៣ថ្ងៃ ចាប់ពីថ្ងៃទី២៧-២៩ ខែមីនា ឆ្នាំ២០២៤។ ដំណើរកម្សាន្តនេះមានអ្នកចូលរួមសរុបចំនួន ២១នាក់ (ស្រី ១០នាក់) ក្នុងនោះមានប្រតិបត្តិករ ១៩ស្ថានីយ និង១ក្រុមហ៊ុន។



*រូបភាពទី៤៣ - ដំណើរកំសាន្តរបស់សមាជិក*

# ៤. ភាពជាតំណាងឱ្យសមាជិក

## ៤.១ កិច្ចសហប្រតិបត្តិការថ្នាក់ជាតិ

### ៤.១.១ កិច្ចសហប្រតិបត្តិការជាមួយក្រសួង/មន្ទីរ ឧ.វ.ប.ន.

- ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ **លោក សៀ សេងហ៊ាប** ហេរញ្ញិក និង **លោក លឹម មិញ** នាយកប្រតិបត្តិនៃសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងឧ.វ.ប.ន.។ ក្នុងនោះដែរ **លោក លឹម មិញ** បានចូលរួមជាវាគ្មិនក្នុងការពិភាក្សាក្រោមប្រធានបទ«**ការបំពេញតួនាទីភាពជាដៃគូសហប្រតិបត្តិការដើម្បីសម្រេចគោលដៅទី៦នៃក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា**»។




*រូបភាពទី៤៤-កម្មវិធីបើកអង្គសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ របស់ក្រសួង ឧ.វ.ប.ន.*




*រូបភាពទី៤៥-កិច្ចពិភាក្សាលើប្រធានបទការបំពេញតួនាទីភាពជាដៃគូសហប្រតិបត្តិការដើម្បីសម្រេចគោលដៅទី ៦*

❖ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម បានជួបប្រជុំជាមួយ លោកប្រធាន និង អនុប្រធានមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ចាម ដើម្បីពិភាក្សាពីការងារ និងកិច្ចសហការរវាងមន្ទីរ និងសមាគម ដែលមានអ្នកចូលរួមសរុបចំនួន ៨នាក់ (ស្រី ៣នាក់)។ របៀបវារៈនៃកិច្ចប្រជុំរួមមាន៖

១. បង្កើនកិច្ចទំនាក់ទំនងគ្នារវាងមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ចាម និងសមាគម
២. ពិភាក្សាអំពីបញ្ហារបស់ប្រតិបត្តិករ និងសិក្សាពីដំណោះស្រាយដែលបានអនុវត្តកន្លងមក
៣. សមាគមស្នើសុំឱ្យមានកិច្ចប្រជុំប្រចាំត្រីមាសរវាងប្រតិបត្តិករក្នុងខេត្ត និង ឯកឧត្តមអភិបាលខេត្ត ឬ អភិបាលរងខេត្ត និងមន្ទីរ ឧ.វ.ប.ន.
៤. សមាគមគោរពអញ្ជើញ លោកប្រធានមន្ទីរ ឧ.វ.ប.ន. ចូលរួមជាគណៈអធិបតីបើកក្នុងកិច្ចប្រជុំថ្នាក់តំបន់។

ជាលទ្ធផល លោកប្រធាន និងអនុប្រធានមន្ទីរ រីករាយក្នុងការផ្តល់កិច្ចសហការជាមួយសមាគមក្នុងការដោះស្រាយបញ្ហារបស់ប្រតិបត្តិករជាសមាជិកសមាគម ឯកភាព និងគាំកិច្ចសហការជាមួយសមាគមក្នុងការរៀបចំកិច្ចប្រចាំប្រជុំត្រីមាសជាមួយប្រតិបត្តិករក្នុងខេត្តកំពង់ចាម។




*រូបភាពទី៤៦- កិច្ចប្រជុំរវាងសមាគម និងមន្ទីរ ឧ.វ.ប.ន. ខេត្តកំពង់ចាម*

❖ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ សមាគម និងសមាជិកបានចូលរួមក្នុង«**វេទិកាទឹកស្អាត**» នៅសណ្ឋាគារសុខាភ្នំពេញ ដែលរៀបចំឡើងដោយក្រសួង ឧ.វ.ប.ន.។




*រូបភាពទី៤៧- សមាគម និងសមាជិកបានចូលរួមក្នុងវេទិកាទឹកស្អាត*

❖ ថ្ងៃទី១១-១២ ខែកញ្ញា ឆ្នាំ២០២៤ សមាគមសហការជាមួយក្រសួង ឧ.វ.ប.ន. និង Informa Market ក្នុងការរៀបចំសិក្ខាសាលា និងពិព័រណ៍ឧស្សាហកម្មវិស័យសំណង់ អគារ វិស្វកម្ម និងឧស្សាហកម្មវិស័យទឹកខ្វាតអន្តរជាតិធំជាងគេនៅកម្ពុជា ២០២៤ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ សិក្ខាសាលា និងពិព័រណ៍មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង និងតំណាងមកពីក្រសួងពាក់ព័ន្ធ តំណាងដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ជាតិ និងអន្តរជាតិ ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការប្រតិបត្តិ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនផ្គត់ផ្គង់ផលិតផល និងសេវាកម្ម និងសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ ទន្ទឹមនឹងនោះ ក៏មានការតាំងបង្ហាញផលិតផល និងសេវាកម្មពាក់ព័ន្ធនឹងវិស័យទឹកស្អាត និងសំណង់ផងដែរ។




*រូបភាពទី៤៨- ការផ្តល់កិត្តិយសកាត់ខ្សែបូបើកកម្មវិធីដោយ **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី*




*រូបភាពទី៤៩- កិច្ចពិភាក្សាពីតំណាងក្រសួងពាក់ព័ន្ធ*

- ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ សមាគមបានទទួលជួបប្រជុំជាមួយ ប្រធាននាយដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង និងសហការីនៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួងឧ.វ.ប.ន. នៅការិយាល័យសមាគម ដើម្បីពិភាក្សាអំពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ការគ្រប់គ្រងទឹកគ្មានចំណូល**»ជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។



*រូបភាពទី៥០- កិច្ចប្រជុំជាមួយប្រធាននាយដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង និងសហការី*

## ៤.១.២ កិច្ចសហប្រតិបត្តិការជាមួយក្រសួង និងដៃគូអភិវឌ្ឍន៍នានា

- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុងសិក្ខាសាលាស្តីពី«**យុវជនដឹកនាំក្នុងវិស័យទឹកស្អាត និងអនាម័យ**» ដែលរៀបចំដោយអង្គការ Center for Sustainable Water (CSW) និងឧបត្ថម្ភដោយកម្មវិធី CAPRED។
- ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុង«**សន្និបាតមីក្រូហិរញ្ញវត្ថុឆ្នាំ២០២៤**» ដែលរៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA)។

- ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុងសិក្ខាសាលាបញ្ជ្រាបការយល់ដឹងស្តីពី«**ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គការសង្គមស៊ីវិល**» ដែលរៀបចំដោយនិយ័តករគណនេយ្យ និងសវនកម្ម។




*រូបភាពទី៥១- សិក្ខាសាលាស្តីពី«ស្តង់ដាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គការសង្គមស៊ីវិល»*

- ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានចូលរួមក្នុងវេទិកាស្តីពី«**ភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល លើកទី៦**» ដែលរៀបចំដោយក្រសួងមហាផ្ទៃ។

## ៤.២ កិច្ចសហប្រតិបត្តិការអន្តរជាតិ

### ៤.២.១ សិក្ខាសាលាស្តីពី«ប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត»

- ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ បុគ្គលិកសមាគមចំនួន ៣នាក់ បានចូលរួមក្នុងសិក្ខាសាលាស្តីពី«**ការសិក្សាលើកទី១ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត**» នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តសៀមរាប រៀបចំដោយក្រុមហ៊ុន GOCRAFT ក្រោមកិច្ចសហការរៀបចំជាមួយក្រសួង ឧ.វ.ប.ន. និងសមាគម KOWBA។ សមាសភាពអ្នកចូលរួម អញ្ជើញមកពីក្រសួង ឧ.វ.ប.ន. រដ្ឋាករទឹកសាធារណៈ (ស្ទោង សៀមរាប ស្វាយរៀង និងស្ទឹងត្រែង) ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ចំនួន ១០ស្ថានីយមកពីខេត្តចំនួន ៥ បុគ្គលិកសមាគម CWA សមាគម KOWBA និងក្រុមហ៊ុន GOCRAFT។




*រូបភាពទី៥២- សិក្ខាសាលាស្តីពី «ការសិក្សាលើកទី១ អំពីអំពីប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត»*

- ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម បានចូលរួមសិក្ខាសាលាស្តីពី«**ការសិក្សាលើកទី២ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត**» នៅសាលប្រជុំនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីធ្វើការសិក្សាទីផ្សារ ណែនាំពីផលិតផលផ្សព្វផ្សាយ និងពង្រីកឲ្យបានទូលំទូលាយនូវការប្រើប្រាស់ប្រព័ន្ធ។




*រូបភាពទី៥៣- សិក្ខាសាលាស្តីពី «ការសិក្សាលើកទី២ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ទឹកស្អាត»*

## ៤.២.២ សិក្ខាសាលាទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន

ក្នុងឆ្នាំ២០២៤នេះ សមាគមបានសហការជាមួយ សមាគមអាជីវកម្មទឹកក្រៅប្រទេស ក្រុងគីតាយូស៊ី (KOWBA) ក្រសួង ឧ.វ.ប.ន. អង្គភាពទឹកស្អាត និងប្រព័ន្ធអនាម័យទីក្រុងគីតាយូស៊ី សិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យកម្ពុជា-ជប៉ុន ចំនួន ២លើក៖

- **លើកទី ១៖** ថ្ងៃទី១៦-១៧ ខែមករា ឆ្នាំ២០២៤ សិក្ខាសាលាស្តីពី«**ទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា ជប៉ុន ២០២៤ លើកទី១៦**»។



*រូបភាពទី៥៤-សិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន*

សិក្ខាសាលាមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួង ឧ.វ.ប.ន. មន្ត្រីស្ថានទូតជប៉ុន មន្ត្រីក្រសួងសុខាភិបាល ការងារ និងសង្គមកិច្ចជប៉ុន មន្ត្រីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ប្រតិភូអង្គភាព

ទឹកស្អាត និងប្រព័ន្ធអនាម័យទីក្រុង គីតាយូស៊ុ និង ប្រតិភូសមាគមអាជីវកម្មទឹកក្រៅប្រទេស ក្រុងគីតាយូស៊ុ ប្រតិភូក្រុមហ៊ុនឯកជនជប៉ុន ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម និង ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ សិក្ខាសាលាមានគោលដៅផ្តល់បច្ចុប្បន្នភាពវិស័យទឹកស្អាតរបស់កម្ពុជា បញ្ហាប្រឈម ការប្រែក្លាយពីអង្គភាពរដ្ឋាករទឹកជាសហគ្រាសសាធារណៈ និងការពិភាក្សាពីកិច្ចដំណើរការប្រតិបត្តិការរបស់រដ្ឋាករទឹកសាធារណៈ និងប្រតិបត្តិករឯកជន ក៏ដូចជាបង្ហាញពីបច្ចេកវិទ្យាថ្មីៗសម្រាប់ការគ្រប់គ្រងទឹកស្អាត តាមរយៈការធ្វើបទបង្ហាញ និងការតាំងពិព័រណ៍ពីក្រុមហ៊ុនជប៉ុន។ ក្នុងកំឡុងសិក្ខាសាលានេះក៏មានការធ្វើបទបង្ហាញស្តីពី៖

១. ការផ្គត់ផ្គង់ទឹកស្អាតកម្ពុជា៖ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមដោយ **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួង ឧ.វ.ប.ន.
២. ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមរបស់រដ្ឋាករទឹកសាធារណៈខេត្តស្វាយរៀង
៣. បញ្ហាប្រឈមក្នុងការពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាត និងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដោយសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
៤. ការបង្ហាញពីសមិទ្ធផលរបស់ក្រុមហ៊ុនឯកជន ជប៉ុនទាំង១១
៥. ការចែករំលែកបទពិសោធន៍របស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ។

ទន្ទឹមនេះសិក្ខាសាលាបានបែងចែកសិក្ខាកាមជា ៤ក្រុមដើម្បីពិភាក្សា និងការធ្វើបទបង្ហាញទៅលើ៖ ក្រុមទី១៖ ទ្រព្យ ក្រុមទី២៖ ប្រតិបត្តិការ ក្រុមទី៣៖ ការគ្រប់គ្រងទិន្នន័យ និងក្រុមទី៤៖ អាជីវកម្ម។




*រូបភាពទី៥៥-កិច្ចពិភាក្សាលើបញ្ហាប្រឈមក្នុងការពង្រីកសេវាផ្គត់ផ្គង់ទឹកស្អាត និងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត*

- **លើកទី២៖** ថ្ងៃទី២៤-២៥ ខែធ្នូ ឆ្នាំ២០២៤ សិក្ខាសាលាស្តីពី«**ទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន**» លើកទី១៧ ក្រោមអធិបតី **ឯកឧត្តម ស៊ឹម ស៊ីថា** រដ្ឋលេខាធិការនៃក្រសួងឧ.វ.ប.ន. ដោយបង្ហាញការវិវត្តជឿនលឿននៃបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធនៃប្រទេសកម្ពុជា និងជប៉ុនក្នុងវិស័យទឹកស្អាត និងអនាម័យ។ សិក្ខាសាលារយៈពេលពីរថ្ងៃនេះ ប្រមូលផ្តុំដោយអ្នកជំនាញ អ្នករៀបចំគោលនយោបាយ និងភាគីពាក់ព័ន្ធប្រមាណ ៣០០នាក់ មកពីប្រទេសទាំងពីរ ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនប្រមាណ ៦២ស្ថានីយ។ សិក្ខាសាលាក៏បានធ្វើការពិភាក្សាជាក្រុមដោយផ្តោតលើ៖ ស្ថានភាពលើ

វិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា និងប្រព័ន្ធទឹកស្អាតដែលមានបច្ចេកវិទ្យាទំនើប។ ក្រោយបិទបញ្ចប់សិក្ខាសាលា សមាគមក៏បានសម្របសម្រួលទស្សនកិច្ចសិក្សាទៅស្ថានីយទឹកស្អាត ឡេង ខៀវ ព្រែកអំបិល សម្រាប់ក្រុមការងារមកពីប្រទេសជប៉ុនផងដែរ។




*រូបភាពទី៥៦- សិក្ខាសាលាស្ដីពីទឹកស្អាត និងប្រព័ន្ធអនាម័យ កម្ពុជា-ជប៉ុន ២០២៤ លើកទី១៧*

## ៤.២.៣ កិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនអន្តរជាតិ

- ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ នាយកប្រតិបត្តិសមាគម បានទទួលជួបប្រជុំសម្ដែងការគួរសមជាមួយ **Mr. YAMAMOTO Koji** ប្រធានថ្មីរបស់ក្រុមហ៊ុនសេវាទឹកទីក្រុងគីតាយូស៊ូ ជំនួស **Mr. ARITA Hitoshi** ដែលបានចូលនិវត្តន៍ ដើម្បីរឹតចំណងមិត្តភាព សាមគ្គីភាព និងបង្កើនកិច្ចសហការជាមួយគ្នា។



*រូបភាពទី៥៧- កិច្ចប្រជុំសម្ដែងការគួរសមជាមួយ លោក YAMAMOTO Koji*

- ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ ជួបប្រជុំជាមួយ **Mr. Masaya USHIDA**, ប្រធានក្រុមហ៊ុន Hitz Hitachi Zosen និងសហការីស្ដីពីការរៀបចំសិក្ខាសាលាក្នុងការបង្ហាញផលិតផលប្រព័ន្ធចម្រោះទឹកស្អាតដោយប្រព័ន្ធក្អាសសរសៃលឿន ( Rapid Fiber Filtration System) ដែលគ្រោងនឹងរៀបចំនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគាររីវើសាយ ខេត្តពោធិ៍សាត់។




*រូបភាពទី៥៨- កិច្ចប្រជុំជាមួយ Mr. Masaya USHIDA, ប្រធានក្រុមហ៊ុន Hitz Hitachi Zosen និងសហការី*

### ៤.២.៤ សិក្ខាសាលាស្តីពី បច្ចេកទេសប្រព័ន្ធចម្រោះទឹក

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៤ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសម្របសម្រួលអញ្ជើញសិក្ខាកាម ចំនួន ២៣ស្ថានីយ ដើម្បីចូលរួមសិក្ខាសាលាស្តីពីបច្ចេកទេសប្រព័ន្ធចម្រោះទឹក ដែលរៀបចំដោយក្រុមហ៊ុន Hitachi Zosen Corporation នៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។



*រូបភាពទី៥៩៖ ការចូលរួមសិក្ខាសាលាស្តីពី«បច្ចេកទេសចម្រោះទឹក» នៅខេត្តពោធិ៍សាត់*

### ៤.២.៥ ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូសាធារណរដ្ឋឥណ្ឌា

សមាគមបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាជូនគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ចំនួន ៧នាក់ ដើម្បីសិក្សារៀនសូត្របន្ថែមអំពីការផ្គត់ផ្គង់ទឹកស្អាត នៅប្រទេសកម្ពុជាដែលមានសកម្មភាពដូចខាងក្រោម៖

- ❖ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ទស្សនកិច្ចសិក្សាទៅកាន់រោងចក្រ... 



*រូបភាពទី៦០- ទស្សនកិច្ចសិក្សាទៅកាន់រោងចក្រទឹកស្វយ័តក្រុងភ្នំពេញ*

- រសៀលថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤ ចូលជួបសម្តែងការគួរសម និងសិក្សាស្វែងយល់ពីគោលនយោបាយ និងច្បាប់គតិយុត្តទាក់ទងទៅនឹងការផ្តល់អាជ្ញាបណ្ណ និងការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា ពីក្រសួង ឧ.វ.ប.ន. ក្រោមអធិបតីភាព ឯកឧត្តម រដ្ឋលេខាធិការ និងឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាតនៅទីស្តីការក្រសួង។



*រូបភាពទី៦១- គណៈប្រតិភូសាធារណរដ្ឋឥណ្ឌា និងថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន.*

- ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៤ ស្វែងយល់អំពីការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតរបស់សហគមន៍ស្មសានរាជធានីភ្នំពេញ និងទស្សនកិច្ចសិក្សានៅ រោងចក្រទឹកស្ទោង-តាំងក្រសាំង (ស្ទោង) ខេត្តកំពង់ធំ។



*រូបភាពទី៦២- ការស្វែងយល់អំពីការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតរបស់សហគមន៍ស្មសាន*

❖ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ សមាគមបានរៀបចំដំណើរទស្សនាចរណ៍មួយសម្រាប់គណៈប្រតិភូសាធារណរដ្ឋឥណ្ឌាទៅទស្សនា ប្រាសាទអង្គរវត្ត ប្រាសាទតាព្រហ្ម និងប្រាសាទបាយ័ន។



*រូបភាពទី៦៣- គណៈប្រតិភូបានអញ្ជើញទស្សនានៅប្រាសាទអង្គរវត្ត*

❖ ព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ សមាគមបានដឹកនាំគណៈប្រតិភូសាធារណរដ្ឋឥណ្ឌា ទៅទស្សនកិច្ចសិក្សានៅស្ថានីយចម្រោះទឹកកខ្វក់ ខេត្តសៀមរាប។



*រូបភាពទី៦៤- គណៈប្រតិភូសាធារណរដ្ឋឥណ្ឌាទស្សនកិច្ចសិក្សានៅស្ថានីយព្រោះទឹកកខ្វក់ ខេត្តសៀមរាប*

❖ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៤ សមាគមបានដឹកនាំគណៈប្រតិភូសាធារណរដ្ឋឥណ្ឌាធ្វើទស្សនកិច្ចសិក្សាអំពីចង្វាក់ផលិតកម្មនៃការផលិតទឹកស្អាតនៅរដ្ឋាករទឹកស្វយ័តសៀមរាប (ភូមិទឹកវិល)។



*រូបភាពទី៦៥- គណៈប្រតិភូសាធារណរដ្ឋឥណ្ឌាទស្សនកិច្ចសិក្សានៅរដ្ឋាករទឹកស្វយ័តសៀមរាប (ភូមិទឹកវិល)*

## ៤.២.៦ សន្និសីទ និងពិព័រណ៍ទឹកអន្តរជាតិ

### ក. សន្និសីទ និងពិព័រណ៍ទឹកលើកទី១៣ (ASIA WATER)

តបតាមការអញ្ជើញរបស់សមាគមទឹកម៉ាឡេស៊ី (MWA) អគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧ.វ.ប.ន. មន្ទីរឧ.វ.ប.ន. ខេត្តកំពង់ស្ពឺ និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ព្រមទាំងសមាជិកសមាគម សរុបចំនួន ២១នាក់(ស្រី ៨នាក់) ក្នុងនោះសមាជិកសមាគមមានចំនួន ១៧នាក់(ស្រីចំនួន ៧នាក់) មកពី ១៤ ស្ថានីយ បានចូលរួមសន្និសីទ និងពិព័រណ៍ទឹកលើកទី១៣ របស់ ASIA WATER ចាប់ពីថ្ងៃទី២៣-២៥ ខែមេសា ឆ្នាំ ២០២៤ នៅមជ្ឈមណ្ឌលសន្និបាតកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។



*រូបភាពទី៦៦- ការចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹកលើកទី១៣*

នៅរសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម បានចូលរួមជាវាគ្មិនក្នុងកម្មវិធីជជែកពិភាក្សា«Regional Water Industry Expert Dialogue on Navigating the Water» ដោយបានចែករំលែកពីស្ថានភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា បញ្ហាប្រឈម ដំណោះស្រាយ និងឱកាសវិនិយោគនានានៅប្រទេសកម្ពុជា។




*រូបភាពទី៦៧- សមាគមចូលរួមជាវាគ្មិនក្នុងកម្មវិធីជជែកពិភាក្សាជាអន្តរជាតិ*

### ខ. វេទិកាទឹកពិភពលោកលើកទី១០ នៅប្រទេសឥណ្ឌូនេស៊ី

តបតាមការអញ្ជើញរបស់អង្គការ CAPRED និងអង្គការ Water.org ក្រសួង ឧ.វ.ប.ន. ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ធនាគារសហគ្រាសធុនតូច និងមធ្យម សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ប្រតិបត្តិករជាស្ត្រីដែលជាសមាជិកសមាគម អង្គការ CAPRED និង Water.org ដែល

សរុបទាំងអស់មានចំនួន ២៦នាក់ (ស្រី ១៣នាក់) បានចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ ចាប់ពីថ្ងៃទី១៩-២៥ ខែឧសភា ឆ្នាំ២០២៤ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី។




*រូបភាពទី ៦៨- តំណាងសមាគមចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ ប្រទេសឥណ្ឌូនេស៊ី*

គោលបំណងនៃវេទិកាទឹកពិភពលោកលើកទី១០ផ្តោតទៅលើ៖

១) ការលើកកម្ពស់សារៈសំខាន់នៃទឹកនៅលើរបៀបវារៈនយោបាយពិភពលោក ដោយប្រមូលផ្តុំអ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកជំនាញទឹក និងអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីបញ្ហាទឹកសំខាន់ៗ។

២) តាមរយៈការជំរុញកិច្ចសន្ទនា និងកិច្ចសហការរវាងភាគីពាក់ព័ន្ធនានា វេទិកានេះមានគោលបំណងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទឹកជាសកល និង

៣) ការពិភាក្សា និងកិច្ចព្រមព្រៀងដែលសម្រេចបានក្នុងវេទិកានេះមានគោលបំណងជំរុញសកម្មភាពជាក់ស្តែងឆ្ពោះទៅរកការសម្រេចបាននូវសុវត្ថិភាពទឹក និងការអនុវត្តការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព។



*រូបភាពទី៦៩- តំណាងក្រសួងទាំង៣ បានចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី*



*រូបភាពទី៧០- គណៈប្រតិភូកម្ពុជា ចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី*

## គ. វេទិកាទឹកលើកទី៦ និងពិព័រណ៌ទឹកថៃ

ថ្ងៃទី៣-៥ ខែកក្កដា ឆ្នាំ២០២៤ សមាគមបានដឹកនាំសមាជិករបស់ខ្លួនចូលរួមវេទិកាទឹកលើកទី៦ និងពិព័រណ៌ទឹកថៃ នៅទីក្រុងបាងកក ដែលមានអ្នកចូលរួមសរុប ៥៩នាក់(ស្រី ២៨នាក់)។



*រូបភាពទី៧១- ទស្សនកិច្ចសិក្សានៅស្ថានីយផលិតទឹកស្អាត មហាសារ៉ាត់ (ប្រទេសថៃ)*

## ឃ. វេទិកាទឹកឥណ្ឌូនេស៊ី Indonesia Water Forum 2024

នៅថ្ងៃទី២៨-៣១ ខែសីហា ឆ្នាំ២០២៤ តបតាមការអញ្ជើញរបស់ សមាគមទឹកឥណ្ឌូនេស៊ី (PERPAMSI) ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិសមាគមបានចូលរួមក្នុងវេទិកាទឹកលើកប្រទេសឥណ្ឌូនេស៊ី ២០២៤ និងបានចូលរួមប្រជុំសមាគមទឹកនៅអាស៊ីអាគ្នេយ៍ (Southeast Asian Water Utilities Network (SEAWUN) Initiative)។




*រូបភាពទី៧២- វេទិកាទឹកឥណ្ឌូនេស៊ី ឆ្នាំ២០២៤*



រូបភាពទី៧៣- ប្រជុំសមាគមទឹកនៅអាស៊ីអាគ្នេយ៍

## ង. ទស្សនកិច្ចសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន ( Exposure visit in China)

តបតាមការអញ្ជើញរបស់ក្រុមហ៊ុន ធីស៊ីយូ (TCU) សមាគម មន្ទីរឧ.រ.ប.ន. ខេត្តបាត់ដំបង កំពង់ស្ពឺ កំពង់ចាម និងស្ទឹងត្រែង រដ្ឋាករសាធារណខេត្តស្ទឹងត្រែង និងខេត្តស្វាយរៀង ព្រមទាំងប្រតិបត្តិករឯកជន បានចូលរួមដំណើរទស្សនកិច្ចសិក្សាទៅកាន់រោងចក្រផលិតសម្ភារៈទឹកស្អាតវៃឆ្លាត WPG (Shanghai) Smart Water Public Co., Ltd នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ពីថ្ងៃទី២១-២៤ ខែកញ្ញា ឆ្នាំ២០២៤។



រូបភាពទី៧៤- ទស្សនកិច្ចសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន

## ច. សន្និសីទ និងពិព័រណ៍ទឹកវៀតណាម ២០២៤ ( Vietwater & WETV Expo 2024 )

នៅថ្ងៃទី៥-៧ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានដឹកនាំសមាជិកចំនួន ៤០នាក់(ស្រី ១៧នាក់) ទៅចូលរួមសន្និសីទ និងពិព័រណ៍ទឹកវៀតណាម ២០២៤ (Vietwater & WETV Expo 2024) នៅមជ្ឈមណ្ឌលសន្និបាតជាតិ ក្នុងទីក្រុងហូជីមិញ ប្រទេសវៀតណាម។ គោលបំណង ដើម្បីសិក្សារៀនសូត្របន្ថែមអំពីវិស័យទឹកស្អាត និងបច្ចេកវិទ្យាថ្មីៗ។




*រូបភាពទី៧៥- សមាជិកសមាគមចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹក ឆ្នាំ២០២៤ នៅប្រទេសវៀតណាម*




*រូបភាពទី៧៦- ការទស្សនការតាំងពិព័រណ៍ និងវេទិកាពិភាក្សានៅប្រទេសវៀតណាម*

## ង. វេទិកាទឹក (Water Week) ទីក្រុងហាណូយ

សមាគមបានទៅចូលរួមនៅក្នុងវេទិកាទឹក (Water Week) នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាតជាតិ ទីក្រុងហាណូយ ប្រទេសវៀតណាម។




*រូបភាពទី៧៧- រូបថតជាមួយថ្នាក់ដឹកនាំសមាគមទឹកនៅវៀតណាម និងដៃគូ*

## ៤.២.៧ ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU)

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាលក្ខណៈអន្តរជាតិ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ចំនួន ២ ដូចខាងក្រោម៖

- នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ សមាគម CWA បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយសមាគមទឹកអូស្ត្រាលី (AWA) សម្រាប់រយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៤ ដល់ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៧។




*រូបភាពទី៧៨- ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងសមាគម AWA & សមាគម CWA*

- នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ សមាគម CWA បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសមាគមអាជីវកម្មទឹកក្រៅប្រទេសក្រុងគីតាយុស៊ុ (KOWBA) រយៈពេល ៥ឆ្នាំ ចាប់ពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៩។ ក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា ក៏មានការផ្តល់កិត្តិយសអញ្ជើញចូលរួមជាសាក្សីពីថ្នាក់ដឹកនាំក្រសួង ឧ.វ.ប.ន. នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ប្រទេសជប៉ុន។




*រូបភាពទី៧៩- ការចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងសមាគម KOWBA & សមាគម CWA*

# ៥. ការងារសហការជាមួយដៃគូអភិវឌ្ឍន៍

## ៥.១ គម្រោង«ពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត» គាំទ្រដោយអង្គការ Water.org

### ៥.១.១ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ

#### ក. ការរៀបចំសមតុល្យដើមគ្រាដោយក្រុមហ៊ុន EAST WING AUTIDTING & CONSULTING CO., LTD

ក្រុមហ៊ុន EAST WING AUTIDTING & CONSULTING CO., LTD (EW) បានសហការជាមួយសមាគមក្នុងការជួយដល់សមាជិកគម្រោងដើម្បីអាចចាប់ផ្តើមការងារគណនេយ្យបាន។ ក្រុមហ៊ុនបានជ្រើសរើសប្រតិបត្តិករចំនួន ៥ ស្ថានីយ ដើម្បីគាំទ្រជំនួយបច្ចេកទេសក្នុងការពិនិត្យទិន្នន័យហិរញ្ញវត្ថុ បើកសមតុល្យដើមគ្រាសម្រាប់ឆ្នាំ២០២៣ និងបញ្ចូលប្រតិបត្តិការហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ ចូលក្នុងប្រព័ន្ធគណនេយ្យពេញមួយឆ្នាំជូនប្រតិបត្តិករទាំងប្រាំ (៥) ដោយឥតគិតថ្លៃ។ ស្ថានីយទាំង៥ ដែលបានជ្រើសរើសចូលរួមក្នុងការរៀបចំឯកសារ រួមមាន៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្វាយជ្រះ (ខេត្តក្រចេះ)
២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កន្ទួត (ខេត្តក្រចេះ)
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត លីហេង (ខេត្តកំពង់ចាម)
៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចំការលើ (ខេត្តកំពង់ចាម)
៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សូទ្រនិគម (ខេត្តសៀមរាប)

ជាលទ្ធផលស្ថានីយចំនួន ៤បានរៀបចំបើកសមតុល្យដើមគ្រាសម្រាប់ឆ្នាំ២០២៣ រួចរាល់ និងមានស្ថានីយចំនួន ២ បានបញ្ចូលទិន្នន័យហិរញ្ញវត្ថុក្នុងប្រព័ន្ធគណនេយ្យពេញលេញ E-Water Software។ ប៉ុន្តែមានតែមួយស្ថានីយទេដែលបានបន្តប្រើប្រាស់កម្មវិធីគណនេយ្យ E-Water Software ដោយមានការសម្របសម្រួលពីក្រុមហ៊ុន EW ព្រោះស្ថានីយចំនួន៤ទៀត កំពុងសិក្សាអំពីប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុនផ្សេងទៀត។

#### ខ. វគ្គបណ្តុះបណ្តាលពីក្រុមហ៊ុន BanhJi FinTech Co., Ltd

ក្រោមការឧបត្ថម្ភរបស់អង្គការ Water.org សមាគមបានសហការជាមួយក្រុមហ៊ុន BanhJi FinTech Co., Ltd ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**គោលការណ៍ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់សហគ្រាសផ្គត់ផ្គង់ទឹកស្អាត**» ចំនួនពីរវគ្គ។ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល អ្នកចូលរួមនឹងមានលទ្ធភាព៖

ក. ស្វែងយល់ពីការសម្រេចចិត្តសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណត់កម្រិតនៃសិទ្ធិក្នុងការសម្រេចចិត្តដែលមានសារៈសំខាន់ក្នុងការរៀបចំគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុរបស់ពួកគេ។
ខ. ស្វែងយល់ពីគោលការណ៍ និងនីតិវិធីគណនេយ្យសំខាន់ៗក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ដោយផ្អែកលើ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម។
គ. រៀបចំគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុដែលត្រូវតាមតម្រូវការរបស់សហគ្រាស។

១) វគ្គទី១៖ រៀបចំនៅថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០២៤ នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។ សមាសភាពអ្នកចូលរួមសរុបចំនួន ៦៤នាក់ (ស្រី ២៧នាក់) ដែលអញ្ជើញពីអគ្គនាយកដ្ឋានទឹកស្អាត អង្គការ Water.org ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកក្រុមហ៊ុន BanhJi FinTech Co., Ltd ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សមាគមមីក្រូហិរញ្ញវត្ថុ (CMA) និងសមាគម (CWA)។

២) វគ្គទី២៖ រៀបចំនៅថ្ងៃទី១៨-២០ ខែធ្នូ ឆ្នាំ២០២៤ នៅសណ្ឋាគារហៃយ៉ាត់ រីជិនសុី ភ្នំពេញ។ សមាសភាពអ្នកចូលរួមសរុបចំនួន ៥៦នាក់(ស្រី ៣១នាក់) ដែលអញ្ជើញពីអគ្គនាយកដ្ឋានទឹកស្អាត អង្គការ Water.org ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកក្រុមហ៊ុន BanhJi FinTech Co., Ltd និងសមាគម CWA។



*រូបភាពទី៨០- រូបថតអនុស្សាវរីយ៍ក្នុងវគ្គបណ្តុះបណ្តាល*



*រូបភាពទី៨១- កម្មវិធីបើកវគ្គបណ្តុះបណ្តាល*

## ៥.១.២ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស

### ក. វគ្គបណ្តុះបណ្តាល

សមាគមបានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត និងអង្គការ Water.org រៀបចំវគ្គបណ្តុះបណ្តាលជូនប្រតិបត្តិករ ស្តីពី«**ការកាត់បន្ថយទឹកគ្មានចំណូល**» ចាប់ពីថ្ងៃទី២៥-២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ នៅសណ្ឋាគារហៃយ៉ាត់ រីជិនសុី ភ្នំពេញ។ វគ្គបណ្តុះបណ្តាលនេះ បង្រៀនដោយគ្រូជំនាញអញ្ជើញមកពីប្រទេសឥណ្ឌូនេស៊ី និងមានការរំលែកចំណេះដឹង មេរៀនសូត្រ និងឧបករណ៍ពីការគ្រប់គ្រងទឹកគ្មានចំណូល។ សមាសភាពអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះសរុបមានចំនួន ៥៤នាក់(ស្រី ១២នាក់) ដែលអញ្ជើញពី អគ្គនាយកដ្ឋានទឹកស្អាត តំណាងអង្គការ Water.org កម្ពុជា និងឥណ្ឌូនេស៊ី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣២ស្ថានីយ និងបុគ្គលិកសមាគម។ ក្រោយបញ្ចប់វគ្គ

បណ្តុះបណ្តាល អ្នកចូលរួមនឹងមានលទ្ធភាពស្វែងយកពីទឹកគ្មានប្រាក់ចំណូល អាចរៀបចំផែនការ អនុវត្ត តាមដាន និងវាយតម្លៃសកម្មភាពកាត់បន្ថយទឹកគ្មានប្រាក់ចំណូល។




*រូបភាពទី៨២- រូបថតអនុស្សាវរីយ៍ក្នុងវគ្គបណ្តុះបណ្តាល*




*រូបភាពទី៨៣- សកម្មភាពរបស់អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាល*

## ខ. វគ្គបង្វឹកនៅស្ថានីយផ្ទាល់

សមាគមបានសហការជាមួយ អគ្គនាយកដ្ឋានទឹកស្អាត/មន្ទីរឧ.វ.ប.ន.ក្នុងការផ្តល់វគ្គបង្វឹកតាមស្ថានីយផ្ទាល់។ វគ្គបង្វឹកនេះមានមន្ត្រីបច្ចេកទេស នៃអគ្គនាយកដ្ឋានទឹកស្អាតចូលរួមបានចំនួន ៧ស្ថានីយ និងមន្ទីរ ឧ.វ.ប.ន. ខេត្តព្រៃវែង ខេត្តតាកែវ និងខេត្តក្រចេះ ចូលរួមបានចំនួន ១០ស្ថានីយ។ វគ្គបង្វឹកផ្ទាល់បានរៀបចំជូនសមាជិកចំនួន ៣១ស្ថានីយ។ កម្មវិធីបង្វឹកនេះមានគោលបំណងឲ្យអ្នកចូលរួមបានសិក្សាស្វែងយល់ និងអនុវត្តអំពីការប្រតិបត្តិការ និងថែទាំប្រព័ន្ធសម្អាតទឹក ការតេស្តគុណភាពទឹក និងការកត់ត្រា ដើម្បីបានជាចំណេះដឹង និងដកស្រង់បទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមក។ នៅចុងបញ្ចប់វគ្គបង្វឹក អ្នកចូលរួមអាចមានលទ្ធភាពៈ

១. ពិនិត្យ និងអនុវត្តការធ្វើតេស្តទឹកលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃតាមរយៈឧបករណ៍តេស្តគុណភាពទឹក

២. កំណត់បានចំណុចត្រូវកែលម្អដល់ស្ថានីយលើផ្នែកបច្ចេកទេស និងពន្យល់បានអនុសាសន៍ដែលត្រូវអនុវត្ត។

វគ្គបង្វឹកផ្ទាល់បានរៀបចំជូនសមាជិកចំនួន ៣១ស្ថានីយ ដូចខាងក្រោម៖

*តារាងទី ៨- បញ្ជីឈ្មោះស្ថានីយដែលសមាគមបានចុះសួរសុខទុក្ខ និងផ្ដល់វគ្គបង្វឹក*

| លរ. | ឈ្មោះស្ថានីយ | លរ. | ឈ្មោះស្ថានីយ |
|---|---|---|---|
| **ខេត្តតាកែវ** | | **ខេត្តកំពង់ស្ពឺ** | |
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីនពេជសារ | ១៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត គគ្រួស |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្រពាំងធំ ដានាង | **ខេត្តកំពង់ចាម** | |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កណ្ដឹង | ១៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត តាអុង |
| ៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សំរោងយ៉ោង | ១៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្ពានថ្មី |
| ៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អង្គតាសោម | ២០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មេសរជ្រៃ-សូភាស |
| ៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បូរីជលសារ | ២១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត លីហេង |
| **ខេត្តព្រៃវែង** | | **ខេត្តបន្ទាយមានជ័យ** | |
| ៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រះស្ដេច | ២២ | ក្រុមហ៊ុនហ្រ្គីន ហ្សូន |
| ៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ល្វារំចេក | ២៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំភ្នំលៀប |
| ៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាភ្នំ | ២៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត រហាល |
| ១០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំជ្រៃ | ២៥ | អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ទឹកដោះមានជ័យ |
| **ខេត្តកណ្ដាល** | | **ខេត្តកំពង់ធំ** | |
| ១១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ ព្រែកអំបិល | ២៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទីប្រជុំជនកំពង់ថ្ម |
| ១២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំស្វាយរមៀត | | **ខេត្តកំពត** |
| ១៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រែកជ្រៃ | ២៧ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំតេជោអភិវឌ្ឍន៍ |
| **ខេត្តក្រចេះ** | | **ខេត្តត្បូងឃ្មុំ** | |
| ១៤ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដំរីផុង | ២៨ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រូចឆ្មារ |
| ១៥ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កន្ទួត | ២៩ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បឹងព្រួល |
| ១៦ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្វាយជ្រះ | ៣០ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហេង អេងហ៊ត |
| **ខេត្តបាត់ដំបង** | | | |
| ៣១ | ក្រុមហ៊ុន វ៉ជើរ អ៊ិនវ៉ាយរ៉ិនមិន (ដាប់បែលយូ.អ៊ី) វេនឈ័រ ឯ.ក | | |



*រូបភាពទី៨៤- សកម្មភាពនៃការបង្វឹកស្ដីពី«បច្ចេកទេសផលិតទឹកស្អាត និងការថែទាំប្រព័ន្ធ»*



*រូបភាពទី៨៥- សកម្មភាពអនុវត្តតេស្តគុណភាពទឹក និងធ្វើជ្យារតេស្ត*

### គ. ការឧបត្ថម្ភធនលើឧបករណ៍ជ្យារតេស្ត

គម្រោងបានសម្របសម្រួលក្នុងការទិញឧបករណ៍ជ្យារតេស្តជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន មួយ (១) ស្ថានីយ ក្រោមការឧបត្ថម្ភធនពីគម្រោង។

## ៥.១.៣ ការចូលរួមវេទិកាអន្តរជាតិ

ក្រោមការឧបត្ថម្ភរបស់អង្គការ Water.org សមាគមបានអញ្ជើញ **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត និងបុគ្គលិកសមាគមចូលរួមកម្មវិធីដូចខាងក្រោម៖

១) **វេទិកាទឹកពិភពលោកលើកទី១០៖** ចាប់ពីថ្ងៃទី១៩-២៥ ខែឧសភា ឆ្នាំ២០២៤ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី។

៣) **វេទិកាហិរញ្ញប្បទានសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម៖** នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារ Fairmont Makati ទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន។ ក្នុងវេទិកានោះផងដែរ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគមបានអញ្ជើញចូលរួមជាវាគ្មិនពិភាក្សាលើប្រធានបទស្តីពី«**ទិដ្ឋភាពទូទៅនៃការទទួលបានហិរញ្ញប្បទានសម្រាប់វិស័យទឹក និងអនាម័យ**» ក្នុងកិច្ចសន្ទនាជាអន្តរជាតិ។




*រូបភាពទី៨៦- វេទិកាហិរញ្ញប្បទានសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម*

### ៥.១.៤ ការសម្របសម្រួលកម្ចី

#### ក. ការភ្ជាប់ទំនាក់ទំនងរវាងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុក្នុងការផ្តល់កម្ចីក្នុងវិស័យទឹកស្អាត

១) ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ នាយកប្រតិបត្តិសមាគមបានចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាតុមូលស្តីពី **«ការលើកកម្ពស់វិស័យសម្រាប់លទ្ធភាពទទួលបានទឹកស្អាតដោយសមធម៌នៅកម្ពុជា»**។ កម្មវិធីនេះរៀបចំដោយធនាគារពិភពលោក និងអង្គការ Water.org។

២) គម្រោងបានគាំទ្រប្រតិបត្តិករ ១ស្ថានីយ រៀបចំប្រវត្តិសង្ខេបនៃការផ្គត់ផ្គង់ទឹកស្អាត និងរបាយការណ៍ហិរញ្ញវត្ថុ ដាក់ជូន Water Equity ដើម្បីពិនិត្យ និងសិក្សាលើគម្រោងកម្ចី។ គម្រោងបានសម្របសម្រួលកិច្ចប្រជុំរវាងប្រតិបត្តិករ និងតំណាង Water Equity ដើម្បីពិភាក្សាលម្អិតលើសំណើកម្ចីរបស់ស្ថានីយ។ តំណាង Water Equity បានសួរសំណួរបន្ថែមដើម្បីបញ្ជាក់ និងផ្តល់ព័ត៌មានអំពីប្រាក់កម្ចីរួមមាន៖ ការប្រាក់កម្ចីប្រចាំឆ្នាំប្រហែល ១៤% រយៈពេលកម្ចី ១០ឆ្នាំ និងការទូទាត់សងប្រចាំឆ្នាំ។ ម្ចាស់ស្ថានីយបានសម្រេចចិត្តមិនយកប្រាក់កម្ចីនេះទេ ប៉ុន្តែគាត់នៅតែចង់សិក្សាបន្តអំពីមូលនិធិ Water Equity បន្ថែម។

៣) នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៤ សមាគម ជួបជាមួយមន្ត្រីធនាគារ SME ដើម្បីពិភាក្សាអំពីកិច្ចសហការរវាងសមាគម និងធនាគារ។ សមាគមបានស្នើសុំធនាគារ SME ក្នុងការពិចារណាលើ៖

- ក. បង្កើនទំហំកម្ចីរហូតដល់ ៣លានដុល្លារ សម្រាប់វិស័យទឹកស្អាត
- ខ. បន្ថែមរយៈពេលកម្ចីរហូតដល់ ១៥ឆ្នាំ
- គ. ស្នើសុំកែសម្រួលការទូទាត់សងតាមរដូវកាល ដែលឆ្លុះបញ្ចាំងពីលំហូរសាច់ប្រាក់របស់ប្រតិបត្តិករ
- ឃ. ការបង្កើតឱ្យមានការអនុគ្រោះក្នុងការសងតែការប្រាក់សម្រាប់ប្រតិបត្តិករ ដែលទើបតែបង្កើតស្ថានីយថ្មីៗ
- ង. ជំរុញការសិក្សាកម្ចីរបស់ប្រតិបត្តិករឱ្យបានឆាប់រហ័ស
- ច. ចែករំលែករបាយការណ៍ទិដ្ឋភាពទូទៅនៃប្រាក់កម្ចីរបស់សមាជិកសមាគម។



*រូបភាពទី៨៧- កិច្ចប្រជុំរវាងសមាគម និងធនាគារ SME Bank*

៤) ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ តាមរយៈការគាំទ្ររបស់អង្គការ Water.org សមាគមបានសហការជាមួយធនាគារ Phillip Bank រៀបចំវគ្គបណ្តុះបណ្តាលស្តីពី«ការណែនាំអំពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅ

ប្រទេសកម្ពុជា» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត។ វគ្គបណ្តុះបណ្តាល មានការចូលរួមពីថ្នាក់ដឹកនាំ និងប្រធានសាខានៃធនាគារ Phillip Bank តំណាងអង្គការ Water.org និងបុគ្គលិកសមាគម។ នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលសិក្ខាកាមអាចៈ

ក. ពិពណ៌នាអំពីទិដ្ឋភាពទូទៅនៃវិស័យផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា

ខ. កំណត់អត្តសញ្ញាណរួមនៃដំណើរការអាជីវកម្មទឹកស្អាតឯកជន (ភាពខ្លាំង បញ្ហាប្រឈម និងឱកាស-តម្រូវការរបស់ប្រតិបត្តិករ)

គ. កំណត់ការវិនិយោគសំខាន់ៗក្នុងអាជីវកម្មទឹកស្អាត (ប្រភពទឹក រោងចក្រផលិតទឹកស្អាត ការចែកចាយ ប្រតិបត្តិការ (អគ្គិសនី ម៉ូទ័រ បុគ្គលិក សារធាតុគីមី))

ង. កំណត់ហានិភ័យ និងឱកាសក្នុងការវិនិយោគក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី៤៨- ការចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនសិក្ខាកាម*

៥) សម្របសម្រួលការស្ទង់មតិអំពីតម្រូវការកម្ចីរបស់ប្រតិបត្តិករជូនក្រុមហ៊ុន CGCC។ ជាលទ្ធផល ៨៦ ស្ថានីយមកពី១៦ខេត្តបានឆ្លើយតបនឹងការស្ទង់មតិនេះ ក្នុងនោះ៤៣% ត្រូវការទុនកម្ចីលើសពី៣០ម៉ឺន។

៦) នៅក្នុងឆ្នាំ២០២៤ គម្រោងបានគាំទ្របន្ថែមដល់កិច្ចប្រជុំថ្នាក់តំបន់របស់សមាគមបានចំនួនប្រាំ(៥)ប្រជុំ។ ជាលទ្ធផលនៃកិច្ចប្រជុំ សមាជិកបានរៀនសូត្របន្ថែមអំពីតួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងប្រកាសអនុញ្ញាត ព្រមទាំងមានទទួលបានចំណេះដឹងថ្មីៗលើបច្ចេកវិទ្យាក្នុងវិស័យទឹកស្អាត លក្ខខណ្ឌនានាក្នុងការទទួលបានហិរញ្ញប្បទាន និងលក្ខខណ្ឌនានាដើម្បីចូលរួមសិក្សាផែនការមេដែលគាំទ្រដោយអង្គការ Water.org ផងដែរ។

៧) គម្រោងនេះបានគាំទ្រដល់សន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី ៥។ គោលបំណងនៃព្រឹត្តិការណ៍នេះគឺដើម្បីពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ខណៈពេលដែលការចែករំលែកបទពិសោធន៍ និងបច្ចេកវិទ្យាប្រកបដោយភាពច្នៃប្រឌិតដែលចាំបាច់សម្រាប់ការជំរុញវិស័យទឹកនៅកម្ពុជា។ សន្និសីទនេះបានប្រារព្ធឡើងចាប់ពីថ្ងៃទី៣-៥ ខែធ្នូ ឆ្នាំ២០២៥ ដែលមានអ្នកចូលរួមសរុប ៦៦៨នាក់ រួមទាំងអ្នកបង្កើតគោលនយោបាយ អ្នកជំនាញឧស្សាហកម្ម ដៃគូអភិវឌ្ឍន៍ ស្ថាប័នហិរញ្ញវត្ថុ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនប្រតិភូមកពីប្រទេសអូស្ត្រាលី និងនិស្សិតសាកលវិទ្យាល័យ។

## ខ. ការសម្របសម្រួលកម្ចី

ឆ្នាំ២០២៤ គម្រោងបានសម្របសម្រួលដល់ដំណើរការទទួលបានកម្ចីជូនដល់ប្រតិបត្តិករចំនួន ៦ស្ថានីយដែលមានទំហំទឹកប្រាក់ ២.២៩៥.៥០០ដុល្លារអាមេរិក សម្រាប់ការអភិវឌ្ឍអាជីវកម្ម។

### ៥.១.៥ ការសិក្សាផែនការមេ និងផែនការអាជីវកម្ម

សមាគម និងអង្គការ Water.org បានជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំផែនការមេសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងជ្រើសរើសប្រតិបត្តិករចំនួន ៦ស្ថានីយ ដើម្បីចូលរួមក្នុងគម្រោងសិក្សាផែនការមេនេះ។ គោលបំណងសំខាន់នៃការសិក្សានេះ គឺបង្កើតផែនការមេអាជីវកម្មជូនស្ថានីយទាំង៦ ដោយមានផែនការវិនិយោគច្បាស់លាស់។ ជាលទ្ធផល ក្រុមការងារបានជ្រើសរើសក្រុមហ៊ុន iSEAជាក្រុមហ៊ុនផ្តល់សេវាកម្មទីប្រឹក្សា និងជ្រើសរើសបានសមាជិកចំនួន ៦ស្ថានីយ៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សូទ្រនិគម ខេត្តសៀមរាប
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចំការលើ ខេត្តកំពង់ចាម
៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សាលាលេខ៥ ខេត្តកំពង់ឆ្នាំង
៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ចំលង ខេត្តកណ្តាល



*រូបភាពទី៨៩- ការចុះប្រមូលព័ត៌មាន និងសិក្សាលើហេដ្ឋារចនាសម្ព័ន្ធរបស់ស្ថានីយទឹកស្អាតកំពង់ចំលង*

ក្រុមការងាររបស់អង្គការ Water.org និង សមាគម បានចុះផ្ទៀងផ្ទាត់ទិន្នន័យ និងពិនិត្យប្រព័ន្ធផលិត និងផ្គត់ផ្គង់ទឹកស្អាតរបស់ស្ថានីយទាំង៦។

ដើម្បីសិក្សាពីផែនការមេជូនប្រតិបត្តិករឱ្យបានល្អិត ក្រុមការងារបានជួបប្រជុំជាមួយក្រុមការងារ iSEA ជាប្រចាំ ដើម្បីពិនិត្យ និងពិភាក្សាអំពីកិច្ចសន្យាអនុវត្តគម្រោង វិធីសាស្ត្រ តម្រូវការព័ត៌មាន ទិន្នន័យដែលត្រូវប្រមូលពីប្រតិបត្តិករ ផែនការសកម្មភាពលម្អិតពីការសិក្សាផែនការមេ និងផែនការមេដែលបានសិក្សារួច។

### ៥.១.៦ កិច្ចសម្ភាសជាមួយប្រតិបត្តិករ និងគ្រួសារដែលបានប្រើប្រាស់ទឹកស្អាត

ក្រុមការងារអង្គការ Water.org និងសមាគម បានសម្របសម្រួលការប្រមូលព័ត៌មានស្តីពីផលជះនៃគម្រោងបានចំនួន ២ដង ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

១) ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤ សមាគម និងអង្គការ Water. org បានថតវីដេអូអំពីប្រតិបត្តិករ និងអ្នកប្រើប្រាស់ទឹកស្អាតនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង។

២) ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ សមាគម និងអង្គការ Water. org បានចុះជួបជាមួយម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកណ្ដឹង និងអតិថិជនចំនួន ៣គ្រួសាររបស់ស្ថានីយនេះ ដែលស្ថិតនៅខេត្តតាកែវ។ គោលបំណងនៃការជួបប្រជុំគឺដើម្បីស្វែងយល់អំពីការកែលម្អអាជីវកម្មរបស់ស្ថានីយ និងភាពពេញចិត្តរបស់អតិថិជនក្នុងការប្រើប្រាស់សេវាទឹកស្អាត។



*រូបភាពទី៩០- កិច្ចសម្ភាសជាមួយប្រតិបត្តិករ និងគ្រួសារដែលបានប្រើប្រាស់ទឹកស្អាត*

## ៥.១.៧ កិច្ចសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត

ក្រុមការងារគម្រោងបានជួបប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ សមាគម និងអង្គការ Water.org បានជួបប្រជុំជាមួយមន្ត្រីអគ្គនាយកដ្ឋានទឹកស្អាត ដើម្បីពិភាក្សាអំពីលទ្ធផលនៃការអនុវត្តគម្រោង និងផែនការចុះបង្ហឹកលើបច្ចេកទេសផលិតទឹកស្អាត តាមស្ថានីយនីមួយៗរបស់ប្រតិបត្តិករក្នុងគម្រោង ដែលគាំទ្រដោយអង្គការ Water.org។ សមាសភាពអ្នកចូលរួមសរុបមានចំនួន ៩នាក់(ស្រី ៤នាក់) ដែលអញ្ជើញពី អគ្គនាយកដ្ឋានទឹកស្អាត ចំនួន ២នាក់ តំណាងអង្គការ Water.org ចំនួន ២នាក់ និងបុគ្គលិកសមាគមចំនួន ៥នាក់។



*រូបភាពទី៩១- កិច្ចប្រជុំជាមួយមន្ត្រីអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួង ឧ.វ.ប.ន.*

## ៥.១.៨ កិច្ចប្រជុំក្នុងគម្រោង

នៅក្នុងឆ្នាំ២០២៤ ក្រុមការងាររបស់គម្រោងបានរៀបចំកិច្ចប្រជុំដូចខាងក្រោម៖

១. ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤៖ ក្រុមការងារបានពិភាក្សាជ្រើសរើសក្រុមហ៊ុនប្រឹក្សាយោបល់ និងប្រតិបត្តិករ ចំនួន ៦ស្ថានីយ ដើម្បីរៀបចំផែនការមេ។

២. ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤៖ ក្រុមការងារពិភាក្សាអំពី ១).កិច្ចសន្យាជាមួយក្រុមហ៊ុន iSEA ២).ការងារគណនេយ្យរបស់ប្រតិបត្តិករជាមួយ ក្រុមហ៊ុន EW និងក្រុមហ៊ុន E-Water ៣).របាយការណ៍ពីការចុះផ្ទាល់ទៅកាន់ស្ថានីយទាំង ៣ស្ថានីយ ក្នុងចំណោម ៦ស្ថានីយ និង៤).ពិភាក្សាអំពីគម្រោងបន្ទាប់។



*រូបភាពទី៩២- កិច្ចប្រជុំក្រុមការងារ*

៣. ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ ជួបប្រជុំជាមួយក្រុមការងារសមាគម និងអង្គការ Water.org ដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីការសិក្សាផែនការមេដែលបានអនុវត្តបាន ៣ស្ថានីយកន្លងមក ព្រមទាំងរៀបចំផែនការសម្រាប់ការសិក្សាសម្រាប់ស្ថានីយផ្សេងៗទៀត។

៤. ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ជួបប្រជុំជាមួយក្រុមការងារក្រុមហ៊ុន iSEA អង្គការ Water.org ដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីការសិក្សាផែនការមេដែលបានអនុវត្តបាន ៤ស្ថានីយកន្លងមក ព្រមទាំងរៀបចំផែនការសម្រាប់ការសិក្សាសម្រាប់ស្ថានីយចំនួន ២បន្ថែមទៀត។

៥. ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ ជួបប្រជុំជាមួយក្រុមការងារក្រុមហ៊ុន iSEA និងអង្គការ Water.org ដើម្បីពិភាក្សាអំពីលទ្ធផលនៃការសិក្សាផែនការមេលើផ្នែកបច្ចេកទេស និងទម្រង់ផែនការអាជីវកម្ម។ លើសពីនេះទៀត ក្រុមការងារសមាគម និងអង្គការ Water.org បានពិភាក្សាអំពីគម្រោងថ្មីបន្តដែលនឹងត្រូវអនុវត្តនៅឆ្នាំ២០២៥ ដល់ឆ្នាំ២០២៦។

៦. ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ ក្រុមការងារសមាគមបានជួបប្រជុំជាមួយម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ ៥ ក្រុមហ៊ុន iSEA និងអង្គការ Water.org ដើម្បីពិភាក្សា និងពិនិត្យលើផែនការវិនិយោគសម្រាប់ការរៀបចំផែនការមេ និងផែនការអាជីវកម្ម ៥ឆ្នាំ ក្នុងគម្រោង «ការកែលម្អការគ្រប់ដណ្តប់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ដើម្បីឱ្យប្រជាជនមានទឹកស្អាតប្រើប្រាស់»។

៧. ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមការងារគម្រោង (CWA & Water.org) បានជួបប្រជុំដើម្បីពិភាក្សាឆ្លុះបញ្ចាំងអំពីគម្រោង និងសកម្មភាពសម្រាប់គម្រោងថ្មី។
៨. ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៤ ក្រុមការងារគម្រោង (CWA & Water.org) បានជួបប្រជុំដើម្បីពិភាក្សាលើផែនការសកម្មភាព ផែនការថវិកា និងគម្រោងសំណើថ្មី។




*រូបភាពទី៩៣៖ កិច្ចប្រជុំជាមួយស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ ៥ ក្រុមហ៊ុន iSEA និងអង្គការ Water.org*

## ៥.១.៩ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង

រសៀលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ សមាគមបានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោង ដើម្បីបង្ហាញអំពីលទ្ធផល បញ្ហាប្រឈម និងមេរៀនរៀនសូត្រនៃការអនុវត្តគម្រោងក្នុងរយៈពេលពីរឆ្នាំ។ អ្នកចូលរួមសរុបចំនួន ៣៥នាក់ មកពីស្ថានីយទឹកស្អាត ២៦ស្ថានីយ អង្គការ Water.org ចំនួន ២នាក់ និងបុគ្គលិកសមាគមចំនួន ៤នាក់។



*រូបភាពទី៩៤៖ ពិភាក្សាក្រុមដើម្បីឆ្លុះបញ្ចាំងអំពីគម្រោង*

## ៥.២ គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន» គាំទ្រដោយអង្គការ EMW

❖ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ បុគ្គលិកសមាគមបានចូលរួមសម្របសម្រួលជាមួយអង្គការ EMW, CDRI, ISF-UTS ក្នុងការសម្ភាសន៍អាជ្ញាធរមូលដ្ឋានក្នុងសង្កាត់លោប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ការសម្ភាសន៍នេះផ្តោតលើដំណើរការបង្កើតក្រុម និងការអនុវត្តន៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។ កិច្ចសម្ភាសន៍នេះមានអ្នកចូលរួមសរុបចំនួន៤៧នាក់ ស្រី១៧នាក់។



*រូបភាពទី៩៥- កិច្ចសម្ភាសក្រុមគោលដៅ*

❖ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៤ បុគ្គលិកសមាគមចំនួន ៣នាក់បានចូលរួមកិច្ចប្រជុំក្រុមការងារទឹកស្អាត និងអនាម័យថ្នាក់ស្រុក (DWG) នៅក្រុងព្រៃវែង ដែលគាំទ្រដោយអង្គការ EMW។ ក្នុងកិច្ចប្រជុំនេះ មានអ្នកចូលរួមសរុបចំនួន ២១នាក់ សមាសភាពរួមមាន៖ លោកអភិបាលរងក្រុង មន្ត្រីក្រុង បុគ្គលិកតំណាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង ក្រុមប្រឹក្សាទាំង ៤សង្កាត់ និងបុគ្គលិកសមាគម។ កិច្ចប្រជុំនេះមានរបៀបវារៈសំខាន់ៗដូចខាងក្រោម៖

១) បទបង្ហាញលទ្ធផល និងការរកឃើញបញ្ហានៃការប្រមូលទិន្នន័យប្រភព ដោយ **លោក ស៊ីន ស៊ីម**។

២) បទបង្ហាញលទ្ធផល និងការរកឃើញបញ្ហានៃការធ្វើបច្ចុប្បន្នភាពទិន្នន័យបង្គន់អនាម័យ គ្រួសារក្រីក្រមិនទាន់ទទួលបានសេវាទឹក អនាម័យ ការធ្វើផែនការឆ្លើយតប ការព្យាករណ៍ ODF+ និងលទ្ធផលសម្រេចបានត្រីមាសទី១ តាមបណ្តាស្រុក ក្រុង ដោយ **លោក ម៉ៅ ឈុនហ៊ាង**។

 

*រូបភាពទី៩៦- កិច្ចប្រជុំក្រុមការងារទឹកស្អាត និងអនាម័យថ្នាក់ស្រុក នៅក្រុងព្រៃវែង*

- ថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០២៤ សមាគមបានជួបប្រជុំជាមួយអង្គការ EMW ដើម្បីពិភាក្សាពីការអនុវត្តគម្រោងកន្លងមក  និងរួមគ្នាបង្កើតគម្រោងនៅពេលអនាគតដ៏ខ្លីខាងមុខដើម្បីឱ្យប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាត និងអនាម័យ តាមរយៈប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី៩៧- កិច្ចប្រជុំជាមួយអង្គការ EMW*

- ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានជួបប្រជុំជាមួយអង្គការ EMW ទីប្រឹក្សារបស់មូលនិធិ DFAT ព្រមទាំងដៃគូរបស់អង្គការ EMW (អង្គការ WOMEN អង្គការ DPO) ដើម្បីពិភាក្សាពីការអនុវត្តគម្រោងកន្លងមក និងប្រមូលសំណូមពរ អនុសាសន៍ពីដៃគូអនុវត្តគម្រោងទាំងអស់។



*រូបភាពទី៩៨៖ កិច្ចប្រជុំជាមួយក្រុមការងារអង្គការ EMW  និងទីប្រឹក្សារបស់មូលនិធិ DFAT*

## ៥.៣ គម្រោង«ការពង្រឹងសមត្ថភាពប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងការកសាងសមត្ថភាពអាជ្ញាធរពីការប្រែប្រួលអាកាសធាតុ សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត» គាំទ្រដោយ UTS

### ៥.៣.១ ការចុះបង្វឹកដល់ស្ថានីយ

សមាគមបានផ្តល់វគ្គបង្វឹកផ្ទាល់ដល់ស្ថានីយទឹកស្អាតចំនួន ៤ស្ថានីយស្តីពី«**ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**»។

១) ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ មានអ្នកចូលរួមសរុបចំនួន ១០នាក់ (ស្រី ៥នាក់) ដែលអញ្ជើញមកពីរដ្ឋបាលឃុំត្បែងខ្ពស់ រដ្ឋបាលឃុំសេដ្ឋី តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ តំណាងជនងាយរងគ្រោះ និងតំណាងស្ថានីយទឹកស្អាត។

២) ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកលង្វែក មានអ្នកចូលរួមសរុបចំនួន ៦នាក់ (ស្រី ១នាក់) ដែលអញ្ជើញមកពីក្រុមប្រឹក្សាឃុំស្វាយ តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងតំណាងស្ថានីយទឹកស្អាត។

៣) ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម មានអ្នកចូលរួមសរុបចំនួន ៦នាក់ (ស្រី ២នាក់) ដែលអញ្ជើញមកពីក្រុមប្រឹក្សាឃុំពាម តំណាងជនងាយរងគ្រោះ តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងតំណាងស្ថានីយទឹកស្អាត។

៤) ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតមករា ស្វាយជុក មានអ្នកចូលរួមសរុបចំនួន ៧នាក់ (ស្រី ២នាក់) ដែលអញ្ជើញមកពីក្រុមប្រឹក្សាឃុំស្វាយជុក តំណាងជនងាយរងគ្រោះ តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងស្ថានីយទឹកស្អាត។

ជាលទ្ធផលស្ថានីយទាំង ៤ បានរៀបចំផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ស្ថានីយរបស់ពួកគាត់រៀងខ្លួន ដោយមានការផ្តល់យោបល់ និងឆ្លុះបញ្ចាំងពីអ្នកពាក់ព័ន្ធទៅលើមុខសញ្ញាគ្រោះថ្នាក់ទៅលើប្រព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ជាងនេះទៅទៀត អ្នកពាក់ព័ន្ធទាំងអស់បានស្វែងយល់បន្ថែមពីផែនការរបស់ស្ថានីយនីមួយៗ ក្នុងការការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងមូល។



*រូបភាពទី៩៩- កិច្ចប្រជុំនៅស្ថានីយទឹកស្អាតពាម*

## ៥.៣.២ ការត្រួតពិនិត្យ និងតាមដាន

សមាគមបានតាមដានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទាំង៤ ពីផែនការសុវត្ថិភាពទឹកធន់នឹងអាកាស រួមមាន៖

១). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម បានរៀបចំសំណាញ់ការពារក្បាលបូមទឹកផៅរួចរាល់ និងបានចាក់បង្គោលមួយចំនួនដើម្បីដាក់ស្លាកសញ្ញាសម្គាល់បំពង់ទឹកស្អាត និងព្យាយាមអនុវត្តផែនការបន្តបន្ទាប់ទៀត។

២). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ បានលើកទំនប់ការពាររាំងដោះភក់ និងអាងស្តុកទឹក បានចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរជារៀងរាល់ខែ ដោយបានធ្វើបទបង្ហាញពីផលប៉ះពាល់ពីការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត។ បង្កើនកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីកាត់បន្ថយការខូចខាតបណ្តាញបំពង់ទឹកស្អាត។

៣). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលង្វែក បានធ្វើសំណាញ់ការពារក្បាលបូមទឹកផៅ ចូលរួមកិច្ចប្រជុំជាមួយអាជ្ញាធរ និងផ្សព្វផ្សាយពីផលប៉ះពាល់ការប្រើប្រាស់សារធាតុគីមី និងការចោលសំរាមចូលក្នុងប្រភពទឹក និងបានរៀបចំលិខិតជូនដំណឹងទៅមន្ទីរសាធារណការ ខេត្តកំពង់ឆ្នាំង អំពីការដាក់បណ្តាញបំពង់ទឹកស្អាត។

៤). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតមកកាស្វាយជុក តាមរយៈកិច្ចសហការល្អជាមួយអាជ្ញាធរ ស្ថានីយបានទទួលព័ត៌មានអំពីការជួសជុល ឬធ្វើផ្លូវថ្នល់ និងទទួលបានសិទ្ធិប្រើប្រាស់ទឹកក្នុងស្រះសហគមន៍ក្នុងការផលិត និងផ្គត់ផ្គង់បាន។

## ៥.៣.៣ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ សមាគមបានសហការជាមួយរដ្ឋបាលស្រុកសាមគ្គីមានជ័យរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង«**ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹកសម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា**» នៅសាលាស្រុកសាមគ្គីមានជ័យ។ កិច្ចប្រជុំមានគោលបំណង៖

១. ឆ្លុះបញ្ចាំងពីដំណើរការរៀបចំឯកសារផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត។
២. ឆ្លុះបញ្ចាំងអំពីការរៀបចំ និងអនុវត្តលើវិធានការកាត់បន្ថយពីផលប៉ះពាល់គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត។
៣. បង្ហាញពីលទ្ធផល បញ្ហាប្រឈម និងមេរៀនរៀនសូត្រដែលទទួលបានពីការអនុវត្តគម្រោង។

សមាសភាពអ្នកចូលរួមក្នុងកិច្ចប្រជុំនេះសរុបមានចំនួន ២២នាក់ (ស្រី ១៣នាក់) ដែលអញ្ជើញមកពីរដ្ឋបាលស្រុកសាមគ្គីមានជ័យ ក្រុមប្រឹក្សាឃុំទាំង៥ រួមមាន៖ ឃុំស្វាយ ឃុំស្វាយជុក ឃុំត្បែងខ្ពស់ ឃុំពាម និងឃុំសេដ្ឋី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនក្នុងស្រុកសាមគ្គីមានជ័យ គ្រួសារងាយរងគ្រោះ អង្គការ WaterAid អង្គការ CDRI និងសមាគម។





*រូបភាពទី១០០៖ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង គាំទ្រដោយ UTS*

## ៥.៤. គម្រោង«ជ្រើសរើសប្រតិបត្តិករឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត» គាំទ្រដោយអង្គការ JICA

សមាគមបានសហការជាមួយក្រសួង ឧ.វ.ប.ន. និងទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន(JICA) ក្នុងការអនុវត្តគម្រោងមួយដែលមានឈ្មោះថា**«ជ្រើសរើសប្រតិបត្តិករឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត»**។ គោលបំណងចម្បងរបស់គម្រោងនេះគឺ**«ការរៀនជាមួយគ្នា»** និងមានគោលដៅដើម្បីកែលម្អប្រតិបត្តិករដោយចែករំលែកចំណេះដឹង បំណិន និងបទពិសោធន៍របស់ពួកគេ។ គម្រោងនេះស្វែងរកការអនុវត្តន៍ល្អៗរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងចែករំលែកយ៉ាងទូលំទូលាយជាមួយនឹងប្រតិបត្តិករដទៃទៀត។

ក្រុមការងារបានចុះសិក្សាលម្អិតដល់ស្ថានីយសម្រាប់ប្រតិបត្តិករដែលបានជ្រើសរើសទាំង ១០ស្ថានីយ និងបានសម្រេចជ្រើសរើសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឆ្នើមចំនួន ៥ស្ថានីយ។






*រូបភាពទី១០១- ក្រុមការងារចុះសិក្សាលម្អិតដល់ស្ថានីយ និងប្រភពទឹក*





*រូបភាពទី១០២- ក្រុមការងារចុះសិក្សាពីប្រព័ន្ធម៉ូទ័រចែកចាយទឹក និងស្តុក*

បន្ទាប់ពីការជ្រើសរើសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យយ៉ាងល្អិតល្អន់ ប្រតិបត្តិករមួយចំនួនខាងក្រោមត្រូវបានជ្រើសសម្រាប់ពានរង្វាន់៖

## ក. ជ័យលាភីពានរង្វាន់នៃការអនុវត្តន៍ល្អបំផុត

| | |
|---|---|
| **<u>ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទតូច</u>** | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់កុង |
| **<u>ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទមធ្យម</u>** | **ចំណាត់ថ្នាក់លេខ ១៖** ក្រុមហ៊ុន ឆ្លូង ឌីស្ទ្រីក វ៉ធើរ ស៊ីបផ្លាយ ឯ.ក<br>**ចំណាត់ថ្នាក់លេខ ២៖** ក្រុមហ៊ុន សសរស្តម្ភ វ៉ធើរ ស៊ីបផ្លាយ ឯ.ក |
| **<u>ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទធំ</u>** | **ចំណាត់ថ្នាក់លេខ ១៖** ក្រុមហ៊ុន ខោលបុលទឹកស្អាត ឯ.ក<br>**ចំណាត់ថ្នាក់លេខ ២៖** ក្រុមហ៊ុន ពួកឌីស្ទ្រីក វ៉ធើរ ស៊ីបផ្លាយ ខូ អិលធីឌី |



















*រូបភាពទី១០៣៖ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ប្រគល់ពានរង្វាន់នៃការអនុវត្តន៍ល្អបំផុតជូនប្រតិបត្តិករ*

## ខ. ពានរង្វាន់ គំរូនៃការអនុវត្តន៍ល្អ

| | |
|---|---|
| <u>**ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទតូច**</u> | ១ .ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់កុង |
| <u>**ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទមធ្យម**</u> | ១ .ក្រុមហ៊ុន ឆ្លូង ឱស្រ្ទីក រ៉េជេរ សឺបផ្លាយ ឯ.ក<br>២ .ក្រុមហ៊ុន សសរស្តម្ភ រ៉េជេរ សឺបផ្លាយ ឯ.ក<br>៣ .ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្បែងខ្ពស់ |
| <u>**ចំណាត់ថ្នាក់ប្រតិបត្តិករប្រភេទធំ**</u> | ១ .ក្រុមហ៊ុន ខោលបុលទឹកស្អាត ឯ.ក<br>២ .ក្រុមហ៊ុន ពួកឱស្រ្ទីក រ៉េជេរ សឺបផ្លាយ ខូ អិលធីឌី<br>៣ .ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សូទ្រនិគម |
| *ពានរង្វាន់ពិសេស* | ១. ក្រុមហ៊ុន ខ្មែរ រ៉េជេរ សិបផ្លាយ ហូលឌីង ខូ អិលធីឌី (KWSH) |
























*រូបភាពទី១០៤៖ **ឯកឧត្តម ស៊ឹម ស៊ីថា** និង **ឯកឧត្តម សយ ឥរម្យ** រដ្ឋលេខាធិការ ប្រគល់ពានរង្វាន់គំរូនៃការអនុវត្តន៍ល្អជូនប្រតិបត្តិករ*

បន្ថែមពីនេះទៀត ក្រុមការងារបានចងក្រងសៀវភៅមួយដែលបានប្រមូលផ្តុំបញ្ហាមួយចំនួនដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បាននឹងកំពុងជួបប្រទះ ក៏ដូចជា «**ការអនុវត្តល្អៗ**» ដែលបានជួយដោះស្រាយបញ្ហាទាំងអស់នោះ។ ករណីសិក្សា ឬឧទាហរណ៍ទាំងអស់នេះអាចប្រើជាឯកសារយោងសម្រាប់ប្រតិបត្តិករដ៏ទៃទៀត យកមកអនុវត្តដើម្បីកែលម្អប្រតិបត្តិការរបស់ពួកគេ។ សៀវភៅនេះបានចែករំលែកក្នុងកម្មវិធីសន្និសីទ និងពិព័រណ៍ទឹកស្អាតកម្ពុជា លើកទី៥។

ខាងក្រោមនេះគឺជាតំណភ្ជាប់ក្នុងការទាញយកឯកសារ!

https://www.cwa.org.kh/wp-content/uploads/2025/01/Booklet-of-Essay_Kh.pdf




*រូបភាពទី១០៥- សៀវភៅគំរូនៃការអនុវត្តន៍ល្អ*

## ៦. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ២០២៤ ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគមបានសម្រេចលទ្ធផលសំខាន់ដូចខាងក្រោម៖

១. ទទួលបានលិខិតអនុញ្ញាតលើកលែងពន្ធលើប្រាក់ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ។
២. ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤។

នៅក្នុងឆ្នាំ២០២៤ ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុបានរៀបចំឯកសារ និងជ្រើសរើសក្រុមហ៊ុន **ខេម អឹខោនធីង & ថាក់សឺវីស** (CAM ACCOUNTING & TAX SERVICE) ជាក្រុមហ៊ុនជំនាញ និងឯករាជ្យក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤។ ខាងក្រោមជារបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរាល់ ក្នុងឆ្នាំ២០២៤៖

| **ចំណូល** | **2024** | **2023** |
|---|---|---|
| ១. មូលនិធិម្ចាស់ជំនួយ | $ 46,626 | $ 265,336 |
| ២. សេវាកម្មផ្សេងៗ | $ 218,223 | $ 131,517 |
| ៣. វិភាគទានសមាជិកភាព | $ 87,627 | $ 78,328 |
| ៤. ចំណូលផ្សេងៗ | $ 9,623 | $ 319,649 |
| **ចំណូលសរុប** | **$ 362,099** | **$794,830** |

| **ចំណាយ** | **2024** | **2023** |
|---|---|---|
| ១. ចំណាយបុគ្គលិក | $ 160,206 | $ 148,398 |
| ២. ចំណាយសកម្មភាព | $ 147,870 | $ 500,582 |
| ៣. ចំណាយប្រតិបត្តិការ | $ 39,128 | $ 49,398 |
| **ចំណាយសរុប** | **$ 347,204** | **$ 698,378** |
| **សមតុល្យចុងឆ្នាំ** | **$ 14,895** | **$ 96,452** |

## ៧. បញ្ហាប្រឈម

ក្នុងឆ្នាំ២០២៤ សមាគម និងសមាជិកបានជួបប្រទះនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

### ៧ ១.បញ្ហាប្រឈមរបស់វិស័យទឹកស្អាត

- អ្នកជំនាញលើវិស័យទឹកស្អាតនៅមានកម្រិត
- កំណើននៃការទទួលបានទឹកស្អាតនៅមានកម្រិតទាប
- ការផ្សព្វផ្សាយច្បាប់ និងប្រកាសនៅមានកម្រិត
- ការវិនិយោគលើវិស័យទឹកស្អាតនៅមានកម្រិត

- ❖ សកម្មភាពបំពុលទឹក និងបម្រែបម្រួលអាកាសធាតុមានការកើនឡើង
- ❖ តំបន់ដែលមិនទាន់មានអាជ្ញាបណ្ណជាតំបន់គ្មានសក្តានុពលក្នុងការទាក់ទាញអ្នកវិនិយោគ
- ❖ បម្រែបម្រួលអាកាសធាតុធ្វើឱ្យតំបន់ខ្លះទទួលរងគ្រោះទឹកជំនន់ និងរាំងស្ងួត
- ❖ ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាតនៅមានកម្រិត។

## ៧.២ បញ្ហាប្រឈមរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន

- ❖ ខូចខាតបំពង់ទឹកស្អាតដោយសារការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (ដោយគ្មានសំណង ឬសំណងមិនសមរម្យ)
- ❖ ខ្វះទុនវិយោគ(ការពង្រីកបំពង់ទឹកស្អាត និងរោងចក្រផលិតទឹកស្អាត)
- ❖ មិនទាន់ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរដ្ឋាភិបាល
- ❖ មិនទាន់ទទួលបានការគាំទ្រពីអាជ្ញាធរមូលដ្ឋានពេញលេញ
- ❖ ប្រតិបត្តិករមិនអាចឆ្លើយតបទៅនឹងលក្ខខណ្ឌរបស់ធនាគារ/មីក្រូហិរញ្ញវត្ថុ
- ❖ តំបន់ខ្លះក្នុងអាជ្ញាបណ្ណមិនមានសក្ដានុពលក្នុងការវិនិយោគ (មិនអាចធ្វើបាន)
- ❖ ចំណេះដឹងរបស់ប្រតិបត្តិករលើផ្នែកបច្ចេកទេស និងការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅមានកម្រិត
- ❖ ប្រជាពលរដ្ឋយល់អំពីគុណប្រយោជន៍ទឹកស្អាតនៅមានកម្រិត
- ❖ គុណភាពសេវាកម្មផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករមួយចំនួននៅមានកម្រិត
- ❖ បម្រែបម្រួលអាកាសធាតុធ្វើឱ្យមានការខ្វះខាតប្រភពទឹកមួយចំនួន ជាពិសេសនៅរដូវប្រាំង
- ❖ ចំណេះដឹងរបស់ប្រតិបត្តិករអំពីពន្ធដារនៅមានកម្រិត
- ❖ ប្រតិបត្តិករភាគច្រើនជាលក្ខណៈអាជីវកម្មបែបគ្រួសារ។

## ៧.៣ បញ្ហាប្រឈមរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

- ❖ សមាគមមានការកិច្ចច្រើន និងមានទំនួលខុសត្រូវច្រើន
- ❖ ធនធានមានកម្រិត (ថវិកា និងមនុស្ស)
- ❖ សមាជិកខ្លះមិនមានឆន្ទៈក្នុងការបង់ប្រាក់វិភាគទានប្រចាំឆ្នាំ
- ❖ ប្រតិបត្តិករខ្លះដែលទទួលបានប្រកាសអនុញ្ញាត(អាជ្ញាបណ្ណ)មិនមានឆន្ទៈចូលជាសមាជិកសមាគម
- ❖ សមាគមអាចកសាងសមត្ថភាពជូនប្រតិបត្តិករ ប៉ុន្តែប្រតិបត្តិករមួយចំនួនមិនមានឆន្ទៈក្នុងការកសាងសមត្ថភាពរបស់ខ្លួន។

# ៨. ទិសដៅការងារអនុវត្តឆ្នាំ២០២៥

ដើម្បីសម្រេចឱ្យបាននូវទស្សនវិស័យ និងបេសសកម្ម សមាគមបានដាក់នូវទិសដៅការងារអនុវត្តសម្រាប់ឆ្នាំ ២០២៥ រួមមាន៖

## ៨.១ អភិបាលកិច្ច

- ❖ រៀបចំ និងអនុម័តផែនការយុទ្ធសាស្ត្រសមាគមសម្រាប់ឆ្នាំ២០២៥ - ២០៣០
- ❖ ការងារសមាគមនឹងរៀបចំសន្និបាតលើកទី១៣ ឆ្នាំ២០២៤
- ❖ ដាក់ឲ្យដំណើរការ«មូលនិធិអភិវឌ្ឍន៍សមាជិក និងវិស័យទឹកស្អាត» របស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

- ❖ ប្រជុំក្រុមប្រឹក្សាភិបាលសមាគមប្រចាំត្រីមាស
- ❖ កិច្ចប្រជុំឆ្លុះបញ្ចាំងការងារសមាគមប្រចាំឆ្នាំ២០២៤។

## ៨.២ ការងារជាមួយសមាជិក

- ❖ កិច្ចប្រជុំថ្នាក់តំបន់ ចំនួន ៤ប្រជុំ
- ❖ កិច្ចគាំពារសមាជិក៖ សម្របសម្រួល និងដោះស្រាយបញ្ហារបស់សមាជិក
- ❖ កិច្ចគាំទ្រជំនួយបច្ចេកទេស៖ ការកសាងសមត្ថភាពលើផ្នែកបច្ចេកទេស និងការគ្រប់គ្រងធុរៈកិច្ច
- ❖ ការចុះសួរសុខទុក្ខសមាជិក។

## ៨.៣ កិច្ចសហការជាតិ និងអន្តរជាតិ

- ❖ ចូលរួមសន្និបាតក្រសួង ឧ.វ.ប.ន.
- ❖ រៀបចំសន្និសីទ និងពិព័រណ៍ទឹក (CAMWATER 2025)
- ❖ រៀបចំដំណើរទស្សនកិច្ចសិក្សាជូនសមាជិកនៅក្នុង និងក្រៅប្រទេស
- ❖ ដឹកនាំសមាជិកចូលរួមក្នុងវេទិកា សន្និសីទ និងពិព័រណ៍ទឹកអន្តរជាតិ
- ❖ សហការជាមួយដៃគូក្នុងការរៀបចំសិក្ខាសាលាពាក់ព័ន្ធនិងវិស័យទឹក
- ❖ ស្វែងរកដៃគូក្នុងការចុះអនុស្សារណៈនៃការយោគយល់គ្នា ដើម្បីប្រយោជន៍សមាជិក និងវិស័យទឹកស្អាត។

## ៨.៤ ការងារសហការជាមួយដៃគូអភិវឌ្ឍន៍

- ❖ អនុវត្តគម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» ក្រោមជំនួយឧបត្ថម្ភរបស់អង្គការ Water.org។

## ៨.៥ រដ្ឋបាល និងហិរញ្ញវត្ថុ

- ❖ រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ ដាក់ជូននិយ័តករគណនេយ្យ និងសវនកម្ម (ACAR) និងអគ្គនាយកដ្ឋានពន្ធដារ (GDT)
- ❖ រៀបចំឯកសារ និងជ្រើសរើសសវនករ សម្រាប់ធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៥។




មជ្ឈមណ្ឌលភ្នំពេញ អគារ F
ជាន់ទី២ បន្ទប់លេខ ២៦៩
វិថីសម្ដេចសុធារស

(+៨៥៥) ០១៧ ៧៩៩ ៣៣៧
(+៨៥៥)០៧០ ៧៩៩ ៣៣៧
(+៨៥៥)០៩៧ ៧១ ៧៩ ៩៤៣

www.facebook.com/cwa.org.kh
www.cwa.org.kh
info@cwa.org.kh